ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Nov-2019, 15:21
CMS/CFO: Sann Rada

នៅចំពោះមុខ៖
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen Harding CLARK
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៩
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# សេចក្តីសម្រេចលើសំណើបន្ទាន់ពាក់ព័ន្ធនៅនឹងផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្រោយមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda HOLLIS

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Megan HIRST

**ជនជាប់ចោទ**

នួន ជា

**សហមេធាវីជនជាប់ចោទ នួន ជា**

សុន អរុណ

Doreen CHEN

លីវ សុវណ្ណ

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួល សំណើបន្ទាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្រោយពីមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា("សំណើបន្ទាន់")ដាក់នៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៩[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ដោយបានដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ("ជនជាប់ចោទ") ពីបទឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបទប្រល័យពូជសាសន៍ ហើយបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[2]។ ដោយពិចារណាទៅលើការដាក់ទោសអស់មួយជីវិតចំពោះ នួន ជា និង ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ បានបញ្ចូលការដាក់ទោសទាំងពីរនេះទៅជាការទោសតែមួយដោយជាប់ពន្ធនាគារអស់មួយជីវិត[3]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សេចក្តីសង្ខេបនៃសំអាងហេតុរបស់ខ្លួន និងបានបញ្ជាក់ថា ពេលវេលាកំណត់សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ នឹងត្រូវចាប់ផ្តើមបន្ទាប់ពីការជូនដំណឹងអំពីសាលក្រមដែលមានសម្អាងហេតុពេញលេញ[4]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងអំពីសាលក្រមពេញលេញនេះ ជាភាសាខ្មែរ អង់គ្លេស និងបារាំង នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩("សាលក្រមអង្គជំនុំជម្រះសាលាដំបូង")[5]។

---

[1] សំណើបន្ទាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្រោយពីមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/2។

[2] *សូមមើល*ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ (ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ទំព័រ ៣៨ (ជួរ ២៥) ដល់ ៤១ (ជួរ ១០)។

[3] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E465("សាលក្រមអង្គជំនុំជម្រះសាលាដំបូង") កថាខណ្ឌ ៤៤០១ ដល់ ៤៤០២។

[4] *សូមមើល*ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ (ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ទំព័រ ២ (ជួរ ២៣) ដល់ ៣(ជួរ ២)។

[5] អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ដោយសារសាលក្រមនេះត្រូវបានដាក់ក្រៅម៉ោងសម្រាប់ដាក់ឯកសារផ្លូវការរបស់ អ.វ.ត.ក. ការជូនដំណឹងមានប្រសិទ្ធភាព គឺគិតចាប់ពីថ្ងៃធ្វើការបន្ទាប់ គឺនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩៖ សេចក្តីសម្រេចលើ

2. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចទុកជាមោឃៈនូវសេចក្តីសង្ខេបដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ដោយសារកង្វះផ្នែកទម្រង់ និងសុំឱ្យប្រកាសមោឃភាពសាលក្រមពេញលេញនោះ[6]។ នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បណ្តឹងសាទុក្ខភ្លាមៗនោះ ពុំអាចទទួលយកបាន[7]។

3. នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ នួន ជា និង ខៀវ សំផន បានដាក់សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរៀងៗខ្លួនប្រឆាំងនឹងសាលក្រមពេញលេញ[8]។ នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការបន្ថែមដូចៗគ្នាដល់ភាគី[9]។

4. នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ នួន ជា និង ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២[10]។ នៅក្នុងនោះ នួន ជា បានលើកឡើងនូវកំហុសអង្គហេតុ និង/ឬអង្គច្បាប់ចំនួន ៣៥១ ដែលបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តឡើង។

---

សំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43 កថាខណ្ឌ ១២។

[6] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសាលក្រមដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆកា ឆ្នាំ ២០១៨ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E463/1។

[7] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសង្ខេបសាលក្រមដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ ឯកសារលេខ E463/1/3។

[8] សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F40/1.1។ សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F39/1.1។

[9] សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា និង ខៀវ សំផន ទៅលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43។

[10] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/3/1។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/4/1។

5. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៩ នួន ជា បានដាក់លិខិតផ្ទេរសិទ្ធិមកកាន់អង្គជំនុំជម្រះតុលាការកំពូលដោយបានជូនដំណឹងអំពីគោលបំណងមុនពេលមរណភាព ក្នុងការជ្រើសរើសសមាជិកនៃគ្រួសាររបស់គាត់ និងក្រុមមេធាវីការពារក្ដី ឱ្យបន្តនីតិវិធីជំនួសរូបគាត់ក្នុងករណីដែលគាត់ទទួលមរណភាពរហូតដល់ដំណាក់កាលប្រកាសសាលដីកា[11]។

6. នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៩ នួន ជា បានដាក់សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន[12] និងបានទទួលមរណភាពនៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៩[13]។

7. នៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៩ មេធាវីការពារក្ដី នួន ជា បានដាក់សំណើបន្ទាន់។

8. នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៩ កិច្ចសន្យាការងាររបស់ក្រុមមេធាវីការពារក្ដីត្រូវបានបញ្ចប់[14]។ បន្ទាប់មក នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ ក្រុមមេធាវីការពារក្ដីបានដាក់សំណើបន្ទាន់សុំឱ្យទទួលយកក្រុមរបស់ខ្លួនចូលធ្វើការ[15]។ នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានឆ្លើយតបដោយបានយល់ឃើញថា សំណើនេះពុំស្ថិតក្រោមយុត្តាធិការរបស់ខ្លួនឡើយ ប៉ុន្តែបានបង្គាប់ថា សហមេធាវីការពារក្ដីរបស់ នួន ជា នៅតែអាចចូលមើលសំណុំរឿងក្នុងប្រព័ន្ធ Zylab របស់ អ.វ.ត.ក. និងទទួលការជូនដំណឹងតាមរយៈអ៊ីម៉ែលរហូតដល់មានការបញ្ជាក់បន្ថែមអំពីបញ្ហានេះ[16]។

9. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើ នួន ជា និងបានប្រកាសថា អង្គជំនុំជម្រះនៅតែទទួលពិនិត្យលើសំណើបន្ទាន់នេះ

---

[11] លិខិតរបស់ នួន ជា អនុញ្ញាតឱ្យបុគ្គលដែលត្រូវបានជ្រើសរើសអនុវត្តជំនួសរូបគាត់ក្នុងករណីដែលគាត់ទទួលមរណភាពនៅមុនពេលការបញ្ចប់នៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F46។

[12] សំណើទីមួយរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F47។

[13] លិខិតបញ្ជាក់មរណភាពរបស់ នួន ជា ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/1.1។

[14] ការបញ្ចប់កិច្ចសន្យាការងារជំនួយការផ្នែកច្បាប់ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/4.1.3។

[15] សំណើសុំឱ្យក្រុមមេធាវីការពារក្ដី នួន ជា ចូលធ្វើការវិញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ F46/4។

[16] ការឆ្លើយតបរបស់អង្គជំនុំជម្រះតុលាការកំពូលទៅនឹងឯកសារលេខ F46/2 ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ F46/5។

ពាក់ព័ន្ធទៅនឹង*ក្នុងចំណោមនោះ* ផលប៉ះពាល់នៃមរណភាពរបស់ នួន ជា ទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងការដាក់ពិរុទ្ធភាពជាមូលដ្ឋាន(“សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធី”)[17]។

10. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សារណាតបទៅនឹងសំណើនេះ នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៩[18]។ ដោយទទួលបានការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល[19] សហព្រះរាជអាជ្ញាបានដាក់សារណាតបជាភាសាអង់គ្លេសនៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៩ និងភាសាខ្មែរនៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៩[20]។ ខៀវ សំផន បានឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញានៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៩[21]។

## II. សំណើបន្ទាន់

11. នៅក្នុងសំណើបន្ទាន់ មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណាលើចំណុចដូចខាងក្រោម៖

(ក) ភាពអាចទទួលយកបានតាមទម្រង់

(១)ទទួលយកសំណើបន្ទាន់នេះថា មានសុពលភាព និងត្រឹមត្រូវតាមទម្រង់ ដោយសារមេធាវីការពារក្តីបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី នួន ជា បន្តនីតិវិធីជំនួសរូបគាត់ ឬជាជម្រើស

---

[17] សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើ នួន ជា ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ F46/3(“សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធី”) កថាខណ្ឌ ៨។

[18] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើបន្ទាន់របស់ នួន ជា ពាក់ព័ន្ធទៅនឹងផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីក្រោយពីមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/2/1 (“សារណាតបរបស់សហមេធាវីនាំមុខ”)។

[19] សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់សារណាតបតែមួយភាសាទៅនឹងសំណើបន្ទាន់របស់ក្រុមមេធាវីការពារក្តី នួន ជា ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/2/3។

[20] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើបន្ទាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីក្រោយមរណភាពរបស់ នួន ជា នៅមុខពេលការចេញសាលដីកា (ឯកសារលេខ F46/2) ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/2/4 (“សារណាតបរបស់សហព្រះរាជអាជ្ញា”)។

[21] ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងសច្ចធារណ៍និរទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ (ឯកសារលេខ F46/2/4) ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ F46/2/4/1។

(២)សម្រេចសំណើបន្ទាន់នេះ *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ដើម្បីជាប្រយោជន៍យុត្តិធម៌

(ខ) សម្រេច៖

(១) បញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខពាក់ព័ន្ធនឹង នួន ជា ដែលនៅពេលនោះ សាលក្រមអង្គជំនុំជម្រះសាលាដំបូងនឹងត្រូវចាត់ទុកជាមោឃៈចំពោះ នួន ជា ដោយសារ នួន ជា ទទួលបានការសន្មតថាគ្មានទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ ឬជាជម្រើស

(២) អនុញ្ញាតបន្តកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹង នួន ជា ដើម្បីជាប្រយោជន៍យុត្តិធម៌ ដោយធានាដល់ការបន្តភាពជាតំណាងរបស់ នួន ជា បន្ទាប់ពីមរណភាពតាមរយៈការជ្រើសរើសរបស់គាត់។

(គ) ក្នុងករណីចាំបាច់ ឬសមស្រប ស្នើសុំវិសោធនកម្មវិធានផ្ទៃក្នុងតាមរយៈកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក. ដើម្បីបំភ្លឺវិធានជាធរមានពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនៅក្នុងសំណើបន្ទាន់នេះ។

(ឃ) សម្រេច៖

(១)ក្នុងកម្រិតអប្បបរមា ចេញផ្នែកសម្រេចសេចក្តីជាមុន ដោយសំអាងហេតុពេញលេញនឹងចេញតាមក្រោយក្នុងពេលឆាប់ៗតាមដែលអាចធ្វើបានដោយផ្អែកលើមូលដ្ឋានបន្ទាន់ និង

(២)ចេញដីកាបង្គាប់បណ្តោះអាសន្ននៅមុនពេលសេចក្តីសម្រេចណាមួយលើអង្គសេចក្តីថា ក្រុមមេធាវីការពារក្តី នួន ជា នឹងត្រូវរក្សាទុកសិទ្ធិរបស់ខ្លួនដល់ពេលវេលាសមស្របតាមការយល់ឃើញរបស់អង្គជំនុំជម្រះ ក្រោយពីការចេញសេចក្តីសម្រេចនោះ។

## III. ភាពអាចទទួលយកបាន

12. ជាការកត់សម្គាល់ដំបូង អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការអនុញ្ញាតជាលាយលក្ខណ៍អក្សរបានផ្អែកទៅលើវិធាន ១១២ នៃវិធានផ្ទៃក្នុង[22]។ វិធាន ១១២ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹងបណ្តឹងសើរើទៅលើសាលក្រមស្ថាពរ មិនមែនពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងឡើយ[23]។ ដោយសារយុត្តាធិការលើបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូលបានកម្រិតតាមវិធានផ្ទៃក្នុងសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច ឬសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[24]វិធាន ១១២ នៃវិធានផ្ទៃក្នុងពុំមែនជាមូលដ្ឋានដើម្បីទទួលយកសំណើបន្ទាន់នេះឡើយ។ បន្ថែមលើនេះ ពុំមានភស្តុតាងថ្មីត្រូវបានបង្ហាញ និងពុំមានការបង្ហាញថា "ភស្តុតាងដែលនាំទៅរកការធ្វើសេចក្តីសម្រេចនោះ មានភាពក្លែងបន្លំ ឬខុសការពិត" និងពុំមានការចោទប្រកាន់ថា ចៅក្រមរូបណាមួយ

---

[22] សំណើសុំបន្ទាន់ កថាខណ្ឌ ៦ និង ១៣។

[23] *សូមមើល* វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. វិសោធនកម្មលើកទី ៩ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ (វិសោធនកម្ម)("វិធានផ្ទៃក្នុង") វិធាន ១១២ នៃវិធានផ្ទៃក្នុង បណ្តឹងសើរើ៖"**១.** ទណ្ឌិត ឬក្នុងករណីដែលទណ្ឌិតនោះទទួលមរណភាព សហព័ទ្ធ កូន ឪពុកម្តាយ ឬបុគ្គលដទៃទៀតដែលមានជីវិតរស់រាននៅពេលមរណភាពរបស់ទណ្ឌិត ហើយបានទទួលនូវបណ្តាំជាលាយលក្ខណ៍អក្សរពីទណ្ឌិតឱ្យធ្វើបណ្តឹងសើរើ ឬសហព្រះរាជអាជ្ញាជំនួសឱ្យទណ្ឌិត អាចធ្វើបណ្តឹងសើរើចំពោះសាលក្រម ឬសាលដីកាស្ថាពរទៅអង្គជំនុំជម្រះតុលាការកំពូល ដោយផ្អែកលើ៖ ក)ភស្តុតាងថ្មីត្រូវបានរកឃើញ ១)មិនអាចរកបាននៅពេលជំនុំជម្រះ ហើយការដែលមិនអាចរកបាននេះពុំមែនដោយសារភាគីទាំងស្រុង ឬផ្នែកខ្លះ ដែលជាអ្នកធ្វើបណ្តឹងនោះឡើយ និង ២)មានលក្ខណៈសំខាន់គ្រប់គ្រាន់ដែលនាំឱ្យសាលដីកាមានការប្រែប្រួល ប្រសិនបើផ្តល់ភស្តុតាងនេះឱ្យក្នុងពេលជំនុំជម្រះ ខ)មានការរកឃើញក្នុងពេលថ្មីៗថា ភស្តុតាងដែលត្រូវបានជំនុំជម្រះ និងយកមកធ្វើជាមូលដ្ឋាននៃការផ្តន្ទាទោសនោះ មានការក្លែងបន្លំ ឬ ខុសការពិត ឬ គ)ចៅក្រមដែលបានចូលរួមនៅក្នុងការស៊ើបសួរ ឬការផ្តន្ទាទោសបានប្រព្រឹត្តខុសឆ្គងយ៉ាងធ្ងន់ធ្ងរនឹងក្រមសីលធម៌ ឬបំពានលើតួនាទីក្នុងការស្វែងរកយុត្តិធម៌ ដែលអាចនាំឱ្យមានការបណ្តេញចេញបានតាមវិធានផ្ទៃក្នុងនេះ។ **២.**បុគ្គលដែលដាក់ពាក្យបណ្តឹងសើរើត្រូវដាក់បណ្តឹងនេះទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ហើយត្រូវបញ្ជាក់ឱ្យបានច្បាស់ពីអង្គហេតុ និងអង្គច្បាប់នៅក្នុងបណ្តឹងនោះ។ បន្ទាប់មក នីតិវិធីដែលអនុវត្តសម្រាប់ការជំនុំជម្រះលើបណ្តឹងសាទុក្ខ ត្រូវយកមកអនុវត្តចំពោះបណ្តឹងសើរើ។ **៣.**ដោយយោងទៅលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះតុលាការកំពូលត្រូវព្យាយាមសម្រេចឱ្យបាននូវសម្លេងឯកច្ឆ័ន្ទ។ ប្រសិនបើមិនអាចរកសម្លេងឯកច្ឆ័ន្ទនេះបានទេ សេចក្តីសម្រេចសើរើត្រូវធ្វើឡើងដោយសម្លេងគាំទ្រយ៉ាងហោចណាស់ដោយចៅក្រម ៥ រូបយ៉ាងតិច។ អង្គជំនុំជម្រះតុលាការកំពូល ត្រូវបដិសេធបណ្តឹងចោល កាលបើខ្លួនពិចារណាឃើញថា បណ្តឹងនោះគ្មានមូលដ្ឋានត្រឹមត្រូវ។ កាលបើកំណត់បានថា ពាក្យសុំមានហេតុផលសមស្រប អង្គជំនុំជម្រះតុលាការកំពូលត្រូវមានយុត្តាធិការជំនុំជម្រះលើករណីនេះ ដើម្បីធ្វើសេចក្តីវិនិច្ឆ័យថា តើត្រូវធ្វើការសើរើសាលក្រមនោះ ឬក៏អត់ដោយអនុវត្តតាមនីតិវិធីសម្រាប់បណ្តឹងសាទុក្ខ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

[24] *សូមមើល* វិធាន ១០៤ ដល់ ១០៥ នៃវិធានផ្ទៃក្នុង។

បានប្រព្រឹត្តខុសឆ្គង ឬបំពានលើតួនាទី[25] ដែលជាមូលដ្ឋាននៃបណ្ដឹងសើរើឡើយ។ អាស្រ័យហេតុនេះ ពុំមានមូលដ្ឋានដែលអាចឱ្យអង្គជំនុំជម្រះទទួលយកសំណើនេះ ដោយអនុលោមតាមវិធាន ១១២ នៃវិធានផ្ទៃក្នុងឡើយ។

13. សំណើបន្ទាន់នេះបានលើកបញ្ហាមួយចំនួនដែលត្រូវបានដោះស្រាយនៅក្នុងសេចក្ដីសម្រេចពីមុនរួចហើយ[26] ប៉ុន្តែ មានបញ្ហាខ្លះ ដូចជាថាតើ កិច្ចដំណើរការនីតិវិធីត្រូវបញ្ចប់ និងត្រូវបន្តក្រោយពីមរណភាពរបស់ នួន ជា ដែរ ឬយ៉ាងណា។ ថាតើមរណភាពរបស់គាត់ បាននាំឱ្យនីតិវិធីក្លាយជាស្ថាពរ ដែរ ឬយ៉ាងណា។ ថាតើ សច្ចធារណ៍និរទោសមានអត្ថិភាពរហូតដល់ដំណាក់កាលនីតិវិធីនៃបណ្ដឹងសាទុក្ខ ដែរ ឬយ៉ាងណា ហើយប្រសិនបើដូច្នោះ ថាតើ មរណភាពរបស់គាត់បាននាំឱ្យមានការមោឃភាពសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែរ ឬយ៉ាងណា និងថាតើ ឋានៈនៃការផ្ដល់សំណងនឹងទៅជាបែបណា ទាំងអស់នេះពុំទាន់ដោះស្រាយនៅឡើយ។

14. ដោយសារប្រព័ន្ធច្បាប់របស់ អ.វ.ត.ក. ពុំបានចែងច្បាស់លាស់លើបញ្ហាទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទោះបីជាមានសេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីក៏ដោយ ក៏អង្គជំនុំជម្រះត្រូវប្រើប្រាស់យុត្តាធិការដែលមាន និងឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីជាប្រយោជន៍យុត្តិធម៌[27]ក្នុងការ

---

[25] *សូមមើល* ជាពិសេសមូលដ្ឋាននៃវិធាន ១១២ ក) ដល់ គ) នៃវិធានផ្ទៃក្នុងចែងថា៖ "ក)ភស្តុតាងថ្មីត្រូវបានរកឃើញ ១) មិនអាចរកបាននៅពេលជំនុំជម្រះ ការដែលមិនអាចរកបាននេះពុំមែនដោយសារភាគីទាំងស្រុង ឬផ្នែកខ្លះ ដែលជាអ្នកធ្វើបណ្ដឹងនោះឡើយ និង ២)មានលក្ខណៈសំខាន់គ្រប់គ្រាន់ដែលនាំឱ្យសាលដីកាមានការប្រែប្រួល ប្រសិនបើផ្ដល់ភស្តុតាងនេះឱ្យក្នុងពេលជំនុំជម្រះ។

ខ)មានការរកឃើញក្នុងពេលថ្មីៗថា ភស្តុតាងដែលត្រូវបានជំនុំជម្រះ និងយកមកធ្វើជាមូលដ្ឋាននៃការផ្ដន្ទាទោសនោះ មានការក្លែងបន្លំ ឬ ខុសការពិត ឬ

គ)ចៅក្រមដែលបានចូលរួមនៅក្នុងការស៊ើបសួរ ឬការផ្ដន្ទាទោសបានប្រព្រឹត្តខុសឆ្គងយ៉ាងធ្ងន់ធ្ងរនឹងក្រមសីលធម៌ ឬបំពានលើតួនាទីក្នុងការស្វែងរកយុត្តិធម៌ ដែលអាចនាំឱ្យមានការបណ្ដេញចេញបានតាមវិធានផ្ទៃក្នុងនេះ"។

[26] *សូមមើលខាងលើ* កថាខណ្ឌ ១៩។ សេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធី។ ការឆ្លើយតបរបស់អង្គជំនុំជម្រះទៅនឹងសំណើបន្ទាន់សុំឱ្យទទួលចូលធ្វើការវិញ ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ F46/5។ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសង្ខេបនៃសាលក្រមដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៨ ឯកសារលេខ E463/1/3 កថាខណ្ឌ ១៧។

[27] *សូមមើល* សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E116/1/7 កថាខណ្ឌ ៣០។

ពិចារណាលើអង្គសេចក្តីនៅក្នុងផ្នែកនៃសំណើបន្ទាន់នេះ[28]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះសម្រេចទទួលយកសំណើបន្ទាន់នេះ។

## IV. ការពិភាក្សា

### ក.ការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ

15. ក្រោយពីមរណភាពរបស់ នួន ជា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបញ្ចប់(*គឺបញ្ចប់ចាប់ពីពេលនេះតទៅ*)រាល់កិច្ចដំណើរការនីតិវិធីទាំងអស់មកលើរូបគាត់ ដោយស្របតាមមាត្រា ៧(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងយ៉ាងជាក់លាក់ចំពោះការរំលត់នៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌបន្ទាប់

---

សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសង្ខេបនៃសាលក្រមដែលបានប្រកាសកាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៨ ឯកសារលេខ E463/1/3 កថាខណ្ឌ ១៧។

[28] វិធានស្តីពីនីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌកម្រិតអន្តរជាតិដទៃទៀត បានគាំទ្រវិធីសាស្ត្របែបនេះធ្វើជាមធ្យោបាយក្នុងការសម្រេចបញ្ហាដែលបានកើតឡើងដោយសារផលវិបាកផ្ទាល់នៃនីតិវិធីដែលតុលាការនេះអនុវត្តតាម។ *សូមមើល* "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីយុត្តាធិការ និងអត្ថិភាព" តុលាការព្រហ្មទណ្ឌពិសេសសម្រាប់ប្រទេសលីបង់("STL")សំណុំរឿងលេខ CH/AC/2010/02 អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ៤៥ ដល់ ៤៦ ៤៨។ *រឿងក្តី Prosecutor ទល់នឹង Beqaj* សំណុំរឿងលេខ IT-03-66-R77 "សាលក្រមលើការចោទប្រកាន់អំពីការប្រមាថតុលាការ" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ១៣។ *រឿងក្តីការសាកល្បងអាវុធនុយក្លេអ៊ែរ(ប្រទេសអូស្ត្រាលី ទល់នឹង បារាំង)* តុលាការយុត្តិធម៌អន្តរជាតិ "សាលក្រមចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៧៤" កថាខណ្ឌ ២៣ ("តុលាការមានយុត្តាធិការដែលអនុញ្ញាតឱ្យចាត់វិធានតាមករណីចាំបាច់ [...] ដើម្បីធានាថាការអនុវត្តន៍យុត្តាធិការលើអង្គសេចក្តី ប្រសិនបើ និងនៅពេលត្រូវបានបង្ហាញ ពុំត្រូវបានរារាំង និង[...]ថា មុខនាទីជាមូលដ្ឋានរបស់តុលាការអាចត្រូវបានការពារ")។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Blaškić* សំណុំរឿងលេខ IT-95-14 "សាលដីកាលើសំណើរបស់សាធារណរដ្ឋក្រូអាតសុំឱ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៧" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៣៣ និង ៣៥ (បញ្ជាក់ថា អំណាចជាអត្ថិភាព មានទំនាក់ទំនងយ៉ាជិតស្និទ្ធទៅនឹងបេសកកម្មដែលបានដាក់ឱ្យបំពេញដោយតុលាការព្រហ្មទណ្ឌ និងក្នុងគោលបំណងធានាបានថាមុខនាទីជាមូលដ្ឋានរបស់តុលាការត្រូវបានបំពេញយ៉ាងពេញលេញ)។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Barayagwize* សំណុំរឿងលេខ ICTR-97-19-AR72 "សេចក្តីសម្រេច" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧៦ ("ត្រូវបានទទួលស្គាល់ជាទូទៅថា តុលាការមានសិទ្ធិអំណាចត្រួតពិនិត្យដែលអាចត្រូវបានប្រើប្រាស់ដើម្បីប្រយោជន៍យុត្តិធម៌ [...] ការប្រើប្រាស់សិទ្ធិអំណាចត្រួតពិនិត្យនេះមានមុខងារបីចំណុច៖ ផ្តល់សំណងចំពោះការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ រារាំងការប្រព្រឹត្តខុសក្រមសីលធម៌នាពេលអនាគត និងជំរុញសុចរិតភាពនៃដំណើរការនីតិវិធីតុលាការ") (សេចក្តីបញ្ជាក់បន្ថែម)។

ពីជនជាប់ចោទបានស្លាប់[29]។ ដូចបានពន្យល់នៅក្នុងសេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធី[30] មរណភាពរបស់ នួន ជា មានអានុភាពរាំងស្ទះដំណើរការរបស់អង្គជំនុំជម្រះក្នុងការធ្វើ"សេចក្តីសម្រេចចុងក្រោយលើអង្គច្បាប់ និងអង្គហេតុ"[31]ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខនាពេលអនាគតរបស់គាត់[32]។ ហេតុដូច្នេះ សារណារបស់ក្រុមមេធាវីការពារក្តីពាក់ព័ន្ធទៅនឹងការបញ្ចប់ ឬការបន្តកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខចាត់ទុកជាអសារបង់[33]។

16. អង្គជំនុំជម្រះបញ្ជាក់ថា ការបញ្ចប់កិច្ចដំណើរការនីតិវិធីពុំបានកាត់បន្ថយអានុភាពនៃអ្វីដែលបានសម្រេចកន្លងមកឡើយ។ អាស្រ័យហេតុនេះ សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធី ពុំបានប៉ះពាល់ និងពុំបានកែប្រែការយល់ឃើញនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងទេ។ ការបញ្ចប់នេះត្រឹមតែមានអានុភាពទប់ស្កាត់លទ្ធភាពបន្តកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនាពេលអនាគតណាមួយពីសំណាក់ ឬប្រឆាំងនឹង នួន ជា តែប៉ុណ្ណោះ។

---

[29] សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៥។

[30] សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៦ "យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបង្ហាញថា បើទោះបីជាអង្គជំនុំជម្រះឧទ្ធរណ៍បានចេញសេចក្តីសម្រេចបន្ទាប់ពីមរណភាពរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏ពុំមានសាលដីកាលើបណ្តឹងឧទ្ធរណ៍ត្រូវបានចេញពាក់ព័ន្ធទៅនឹងជនជាប់ចោទដែលនៅមុនពេលស្លាប់បានដាក់បណ្តឹងឧទ្ធរណ៍យ៉ាងត្រឹមត្រូវនៅមុខអង្គជំនុំជម្រះឧទ្ធរណ៍នូវសារណាដែលមានទឡ្ហីករណ៍ និងមានសំអាងហេតុពេញលេញនៃបណ្តឹងឧទ្ធរណ៍ឡើយ។ ចំណុចនេះកាន់តែច្បាស់លាស់បន្ថែមទៀតនៅក្នុងករណីនៃរឿងក្តីបច្ចុប្បន្ន ដែលអង្គជំនុំជម្រះឧទ្ធរណ៍ពុំបានទទួលសារណាពេញលេញលើបណ្តឹងសាទុក្ខ និងពុំស្ថិតក្នុងដំណាក់កាលចាប់ផ្តើមពិភាក្សាសម្រេចលើអង្គសេចក្តីនៃកំហុសអង្គច្បាប់ ឬអង្គហេតុដែលបានចោទប្រកាន់ ដូចបានលើកឡើងជាសង្ខេបនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ"។

[31] មាត្រា ៣៦ *ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. សម្រាប់កាត់សេចក្តីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ រួមបញ្ចូលវិសោធនកម្មដែលបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤។

[32] *សូមមើល* វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។ សេចក្តីសម្រេចស្តីពីសំណើរបស់មេធាវីការពារក្តីសុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ F3/3 កថាខណ្ឌ ៨។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/3/1 កថាខណ្ឌ ៧ ដោយទទួលស្គាល់ថា "ការកំណត់អត្ថសញ្ញាណនៃសេចក្តីយោងចង្អុលបង្ហាញកំហុសទាំងអស់ [... ] អាចពុំមានលក្ខណៈទូលំទូលាយ"។

[33] សំណើបន្ទាន់ កថាខណ្ឌ ១។

## ខ. ការចូលស្ថាពរនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង

### សារណា

*មេធាវីការពារក្តី នួន ជា*

17. មេធាវីការពារក្តី នួន ជា បានលើកឡើងថា ផលវិបាកនៃការបញ្ចប់កិច្ចដំណើរការនីតិវិធីនៅដំណាក់កាលបណ្តឹងសាទុក្ខ ពុំទាន់បានដោះស្រាយនៅឡើយផ្អែកតាមច្បាប់កម្ពុជា និងថា ពុំមានភាពច្បាស់លាស់ថា តើសាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវចាត់ទុកជាស្ថាពរ ដែរ ឬយ៉ាងណា នៅពេលដែលម្ចាស់បណ្តឹងសាទុក្ខស្លាប់ នៅមុនពេលចេញសាលដីកានៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ[34]។ មេធាវីការពារក្តីបានអះអាងថា ការអានផ្គួបគ្នានៃមាត្រា ៣៥ *ថ្មី* មាត្រា ៣៦ *ថ្មី* មាត្រា ៣៧ *ថ្មី* នៃច្បាប់បង្កើតឱ្យមាន អ.វ.ត.ក. ជាមួយវិធាន ១១១(៦) នៃវិធានផ្ទៃក្នុងសន្និដ្ឋានបានថា នៅពេលទទួលរងបណ្តឹងសាទុក្ខ សាលក្រមអង្គជំនុំជម្រះសាលាដំបូងអាចក្លាយទៅជាស្ថាពរបាន ដរាបណាបណ្តឹងសាទុក្ខត្រូវបានបដិសេធចោលលើអង្គសេចក្តីប៉ុណ្ណោះ[35]។

18. មេធាវីការពារក្តីបានលើកឡើងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY ដែលបានបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខចំពោះ *Delić* (បន្ទាប់ពីមរណភាពរបស់គាត់នៅមុនពេលចេញសាលដីកាលើបណ្តឹងសាទុក្ខ) និងបានបញ្ជាក់ថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងចំពោះរូបគាត់ត្រូវចាត់ទុកជាស្ថាពរនោះ គឺពុំអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក. ឡើយ[36]។

*សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី*

19. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងពុំមែនចូលស្ថាពរពាក់ព័ន្ធនឹង នួន ជា និងថា "មានតែអានុភាពផ្នែកអង្គច្បាប់នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ ទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា ដែលពុំមានអត្ថិភាព"[37]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា "វិធានការសំណងដែលបាន

---

[34] សំណើបន្ទាន់ កថាខណ្ឌ ២២។

[35] សំណើបន្ទាន់ កថាខណ្ឌ ៤៥។

[36] សំណើបន្ទាន់ កថាខណ្ឌ ៣៥ និង ៤៤។

[37] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៨។

អនុញ្ញាតដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ត្រូវបានធ្វើឡើងតាមរយៈវិធាន ២៣ *ស្ទួនបួន* ៣(ខ)" ដែលចែងថា ការផ្តល់សំណង"ពុំមែនអាស្រ័យលើអត្ថិភាពនៃសាលក្រមស្ថាពរ"[38] ហើយអាច"ត្រូវបានបង្កើត និងអនុវត្តស្របពេលជាមួយនឹងការជំនុំជម្រះ"[39]ដើម្បីឱ្យ"សំណងនេះអាចសម្រេចបាននៅក្នុងពេលវេលាប្រកបដោយអត្ថន័យ"[40]។ ដោយហេតុថា សំណងសមូហភាព និងផ្លូវចិត្តត្រូវបានទទួលស្គាល់ និងយល់ព្រមដោយអង្គជំនុំជម្រះសាលាដំបូង ជាជាងអាស្រ័យលើសាលក្រម ឬការបង្គាប់តាមរយៈដីកាសម្រេចប្រឆាំងនឹងជនជាប់ចោទ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា មរណភាពរបស់ នួន ជា "ពុំមានផលប៉ះពាល់ទៅលើផ្នែកនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលដោះស្រាយសំណងរដ្ឋប្បវេណីឡើយ"[41]។

*សហព្រះរាជអាជ្ញា*

20. បើទោះបីជាសហព្រះរាជអាជ្ញាបានទទួលស្គាល់ថា ច្បាប់កម្ពុជាចែងអំពីអត្ថិភាពនៃសច្ចធារណ៍និរទោសរហូតដល់សាលក្រមស្ថាពរក៏ដោយ[42] ក៏សហព្រះរាជអាជ្ញានៅតែអះអាងថា ដោយសារ"ភាពខុសប្លែកគ្នារវាងប្រព័ន្ធច្បាប់ជាតិ និង អ.វ.ត.ក."[43] និងភាពពុំស្របគ្នារវាងច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ជាមួយនឹងនីតិវិធីពាក់ព័ន្ធ ក៏ដូចជាការអនុវត្តន៍នៅកម្រិតអន្តរជាតិផងដែរនោះ[44] យុត្តិសាស្ត្រពាក់ព័ន្ធរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ*មិនអាចមិនអើពើ*គប្បីត្រូវយកមកអនុវត្តតាម[45]។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះអនុម័តតាមតួនាទីរបស់អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY ក្នុងការសន្និដ្ឋានថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងចូលជាស្ថាពរ និងពុំមានអ្វីមករារាំងការធ្វើដូច្នេះឡើយ បើទោះបីជានៅដំណាក់កាលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក៏ដោយ។ ផ្អែកតាមសហព្រះ

---

[38] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៩។

[39] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១២។

[40] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១២។

[41] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៣។

[42] មាត្រា ៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ចែងថា"ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។

[43] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

[44] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤ ពាក់ព័ន្ធនឹងមាត្រា ៣៥ *ថ្មី* និង ៣៧ *ថ្មី* នៃច្បាប់ស្តីពីការឱ្យមាន អ.វ.ត.ក.។

[45] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥ ៦ ៧។

រាជអាជ្ញាបានឱ្យដឹងថា តាមវិធានផ្ទៃក្នុង សាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវតែចាត់ទុកជាស្ថាពរ[46]។ សហព្រះរាជអាជ្ញាបានអះអាងថា ការបកស្រាយបែបនេះផ្ទុះបញ្ចាំងការអនុវត្តន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ *មិនអចិន្ត្រៃយ៍*[47]។

*មេធាវីការពារក្តី ខៀវ សំផន*

21. មេធាវីការពារក្តី ខៀវ សំផន បានអះអាងថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងពុំអាចចូលជាស្ថាពរ បើផ្អែកលើវិធាន ១១១(៦) នៃវិធានផ្ទៃក្នុងដែលចែងថា "ក្នុងករណីបណ្តឹងសាទុក្ខត្រូវបានបដិសេធ នោះសាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវចូលជាស្ថាពរ និងមិនអាចតវ៉ាបានទៀតឡើយ"។ ដោយហេតុថា ពុំមានបណ្តឹងសាទុក្ខត្រូវបានបដិសេធនៅក្នុងវិសាលភាពនៃវិធាន ១១១(៦) មេធាវីការពារក្តី ខៀវ សំផន សន្និដ្ឋានថា ដរាបណាសាលក្រមអង្គជំនុំជម្រះសាលាដំបូងនៅតែជាសេចក្តីសម្រេចរបស់តុលាការ ពុំមាន*អាជ្ញាអស់ជំនុំ*ដែលប្រើប្រាស់សម្រាប់សាលក្រមស្ថាពរនោះឡើយ[48]។

**ច្បាប់ជាធរមាន**

(១) ច្បាប់កម្ពុជា និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.

22. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោស*ជាស្ថាពរ* (finally)"[49]។ ក្រមព្រហ្មទណ្ឌកម្ពុជាចែងថា

[46] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣ ជើងទំព័រ ៣៦៖ សហព្រះរាជអាជ្ញាបានលើកឡើងជាពិសេសថា 'ការឃុំខ្លួនបណ្តោះអាសន្ន' គឺត្រូវបានបកស្រាយថាជាការឃុំខ្លួននៅមុន"សាលក្រមស្ថាពរ" ហើយវិធានផ្ទៃក្នុងបានវែកញែកច្បាស់លាស់រវាង'ការឃុំខ្លួនបណ្តោះអាសន្ន' នៅមុនការចេញសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ *សូមមើល* និយមន័យនៃ ការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង៖ "ការឃុំខ្លួនជនត្រូវចោទតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបសួរ ឬអង្គបុរេជំនុំជម្រះ ឬការឃុំខ្លួនជនជាប់ចោទតាមដីការបស់អង្គជំនុំជម្រះ រង់ចាំសាលក្រមស្ថាពរ" ទំព័រ ៨៥។ *សូមមើលផងដែរ* វិធាន ២១(១)(ឃ) និង ៩៩។

[47] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។

[48] ការឆ្លើយតបរបស់ ខៀវ សំផន កាថាខណ្ឌ ៤៤ ដល់ ៤៥។

[49] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

"សេចក្តីសម្រេចត្រូវបានចាត់ទុកថា *ជាស្ថាពរ* (definitive) កាលណាសេចក្តីសម្រេចនេះ មិនអាចមានផ្លូវតវ៉ាបានទៀត ឡើយ"[50]។

23. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា ១) ក្រោយពេលទោសត្រូវបានប្រកាស "អយ្យការធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់តុលាការបានក្លាយទៅ*ជាស្ថាពរ* (final)"[51] ២)"នៅក្នុងរយៈពេលប្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រម[អង្គជំនុំជម្រះសាលាដំបូង]ត្រូវបង្អង់សិន"[52] ៣) "ប្រសិនបើបណ្តឹងសាទុក្ខត្រូវបានបដិសេធ នោះសេចក្តីសម្រេចដែលតវ៉ាមាន*អាជ្ញាអស់ជំនុំ*"[53] និង ៤)ថា *អាជ្ញាអស់ជំនុំ* អនុវត្តចំពោះការសម្រេចឱ្យរួចខ្លួនស្ថាពរ[54]។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាតម្រូវឱ្យសេចក្តីសម្រេចចុងក្រោយត្រូវចេញនៅរៀងរាល់កម្រិតនៃឋានានុក្រមរបស់តុលាការ ក្នុងករណីដែលការចូលជាស្ថាពរនៃសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង អាចធ្វើទៅបានបន្ទាប់ពីឆ្លងកាត់ការដេញដោលតាមរយៈដំណើរការនីតិវិធីពិនិត្យឡើងវិញលើអង្គសេចក្តី ដោយយុត្តាធិការលើបណ្តឹងសាទុក្ខ ដែលមានសិទ្ធិអំណាចសមស្របប៉ុណ្ណោះ[55]។

24. ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ចែងថា អង្គជំនុំជម្រះតុលាការកំពូល"ជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងសម្រេចសេចក្តីចុងក្រោយផង"[56] និងត្រូវសម្រេចបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តី

---

[50] មាត្រា ៩១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩។

[51] មាត្រា ៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧។

[52] មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[53] មាត្រា ៤៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[54] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា "ដោយអនុលោមតាមគោលការណ៍*អាជ្ញាអស់ជំនុំ* ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានចោទប្រកាន់ទៀតពីទេចំពោះអំពើដដែលឡើយ ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ"។

[55] *សូមមើលឧ.* មាត្រា ៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា៖ សាលដីកាដែលសម្រេចជាសមត្ថកិច្ច"ចុងក្រោយ"ដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ អាចត្រូវប្តឹងសាទុក្ខបាន។

[56] មាត្រា ៩ *ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក.។ *សូមមើលផងដែរ* មាត្រា ៣(២)(ខ) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធទៅនឹងការកាត់សេចក្តីតាមច្បាប់កម្ពុជានូវបទឧក្រិដ្ឋដែលបានប្រព្រឹត្ត

សម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង តាមរយៈការធ្វើ“សេចក្តីសម្រេចជាចុងក្រោយទាំងលើអង្គហេតុទាំងអង្គច្បាប់ដោយមិនបង្វិលសំណុំរឿងមកអង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងវិញទេ”[57]។ វិធានផ្ទៃក្នុងបានផ្តល់សិទ្ធិអំណាចដល់អង្គជំនុំជម្រះតុលាការកំពូល ពិនិត្យលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយចេញសាលដីកាស្ថាពរ[58]។ វិធានផ្ទៃក្នុងក៏បានចែងផងដែរថា “ក្នុងករណីដែលបណ្តឹងសាទុក្ខត្រូវបានបដិសេធ នោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវចូលជាស្ថាពរ និងមិនអាចតវ៉ាបានទៀតឡើយ”[59] និងថា “សហព្រះរាជអាជ្ញាធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបានចូលជាស្ថាពរ [...]”[60]។ ពាក់ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះបានបញ្ជាក់ពីដំបូងនៅក្នុងសេចក្តីសម្រេចមុនៗថា “នៅក្នុងបរិបទរបស់ អ.វ.ត.ក. សាលក្រមលើអង្គសេចក្តីពុំមែនចូលជាស្ថាពរ រហូតទាល់តែបានឆ្លងកាត់ដំណាក់កាលបណ្តឹងសាទុក្ខ”[61]។

---

ឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ចុះហត្ថលេខានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ និងចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥(“កិច្ចព្រមព្រៀង”)។

[57] មាត្រា ៣៦ *ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក.។

[58] វិធាន ១០៤(៣) នៃវិធានផ្ទៃក្នុងចែងថា៖ “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល គឺជាសេចក្តីសម្រេចចុងក្រោយ និងមិនត្រូវបង្វិលឱ្យអង្គជំនុំជម្រះសាលាដំបូងវិញឡើយ”។ *សូមមើលផងដែរ* វិធាន ១០៤(៣) និង ១១២ នៃវិធានផ្ទៃក្នុង ចំណងជើងថា “បណ្តឹងសើរើ”។

[59] វិធាន ១១១(៦) នៃវិធានផ្ទៃក្នុង។

[60] វិធាន ១១៣(២) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* ទាក់ទងទៅនឹងការចូលជាស្ថាពរ វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង(សំដៅទៅលើសេចក្តីសម្រេចចុងក្រោយនៅចំពោះមុខអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល) មាត្រា ៦៦ *ស្ទួន* នៃវិធានផ្ទៃក្នុង (សំដៅទៅលើការចូលជាស្ថាពរនៃដីកាសម្រេចពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ) វិធាន ៧៧ *ស្ទួន*(២) នៃវិធានផ្ទៃក្នុង (ចែងថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើការពន្លឿនបណ្តឹងសាទុក្ខត្រូវតែចាត់ទុកជាចុងក្រោយ) មាត្រា ៨០(១) និង ៨៩(១) នៃវិធានផ្ទៃក្នុង(សំដៅទៅលើចំណុចដែលដីកាសម្រេចចោទប្រកាន់ ឬដីកាដំណោះស្រាយ ចូលជាស្ថាពរ) មាត្រា ៨៩ *ស្ទួនបី* (២)នៃវិធានផ្ទៃក្នុង(សំដៅលើការចូលស្ថាពរនៃដីកាសម្រេចពាក់ព័ន្ធនឹងវិសាលភាពនៃការជំនុំជម្រះ)។

[61] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ E163/5/1/13 កថាខណ្ឌ ២៤ *យោង* វិធាន ១០៤, ១១០-១១១, ១១៣ នៃវិធានផ្ទៃក្នុង និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៣៩៨, ៤០៥, ៤០៦, និង ៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

(២) យុត្តិសាស្ត្រអន្តរជាតិ

25. ក្នុង *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Delić និង *រឿងក្តី រដ្ឋអាជ្ញា* Popović *និងជនដទៃទៀត* ដែលក្នុងរឿងក្តីនេះ ជនជាប់ចោទទាំងពីរដែលត្រូវបានសម្រេចដាក់ពិរុទ្ធនៅដំណាក់កាលជំនុំជម្រះបានស្លាប់ក្នុងអំឡុងពេលនៃបណ្តឹងសាទុក្ខ[62] អង្គជំនុំជម្រះឧទ្ធរណ៍ទាំងពីររបស់តុលាការ ICTY បានរកឃើញថា ១) មរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខ បណ្តាលឱ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ ២) លក្ខន្តិកៈ និងវិធាននានា ពុំមានចែងអំពីផលប៉ះពាល់នៃការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខមកលើការចូលជាស្ថាពរនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្រោយពេលមរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខ ហើយនៅមុនពេលចេញសាលដីកា និង ៣) ដោយហេតុថា ពុំមានសាលដីកាដែលត្រូវបានចេញពាក់ព័ន្ធនឹងរឿងក្តីនេះ ដូច្នេះពុំមានអ្វីរាំងដល់ការចូលជាស្ថាពរនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវចាត់ទុកជាស្ថាពរនោះឡើយ[63]។

## **ការពិចារណា**

26. នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. បានប្រើប្រាស់ពាក្យ **definitive** (ស្ថាពរ) និង **final** (ស្ថាពរ) ចំណែកឯនៅក្នុងវិធានផ្ទៃក្នុងបានប្រើប្រាស់តែពាក្យ **final** (ស្ថាពរ)[64]។ ពាក្យ **definitive** មានអត្ថន័យជាភាសាអង់គ្លេសថា

---

[62] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Rasim Delić សំណុំរឿងលេខ IT-04-83-A "សេចក្តីសម្រេចលើផលវិបាកនៃកិច្ចដំណើរការនីតិវិធី" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១០ ("សេចក្តីសម្រេច*រឿងក្តី* Delić") កថាខណ្ឌ ៥។ *រឿងក្តី Prosecutor ទល់នឹង* Popović *និងជនទៃទៀត* សំណុំរឿងលេខ IT-05-88-A "សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹង Milan Gvero" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៣ ("សេចក្តីសម្រេច*រឿងក្តី Gvero*") កថាខណ្ឌ ២ ដល់ ៥។

[63] សេចក្តីសម្រេច*រឿងក្តី* Delić កថាខណ្ឌ ៩ និង ១៥។ សេចក្តីសម្រេច*រឿងក្តី* Gvero កថាខណ្ឌ ៦ ("អង្គជំនុំជម្រះឧទ្ធរណ៍ពិចារណាឃើញថា បន្ទាប់ពីបានរកឃើញថា មរណភាពរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍បណ្តាលឱ្យបញ្ចប់កិច្ចដំណើរការនីតិវិធី និងដោយហេតុថា ពុំមានសាលដីកាលើបណ្តឹងសាទុក្ខត្រូវបានចេញពាក់ព័ន្ធនឹង Gvero ពុំមានអ្វីអាចប៉ះពាល់ដល់ការចូលស្ថាពរនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹង Gvero ឡើយ។ ជាលទ្ធផល សាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវចាត់ទុកជាស្ថាពរទាក់ទងទៅនឹង Gvero")។

[64] *សូមមើល* មាត្រា ៩១ នៃក្រមព្រហ្មទណ្ឌកម្ពុជា និង មាត្រា ១២ ៦៦ ១២៣ ២៥៦ និង ៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ *សូមមើលផងដែរ* វិធាន ៣៤ ១០៤ ១១១ ១១២ និង ១១៣។ *សូមមើលផងដែរ* មាត្រា ៣៥ ថ្មី និង ៣៦ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក.។

**authoritative** (ឱ្យអនុវត្តតាម ឬឱ្យគោរពតាម) ដែលខុសប្លែកគ្នាពីពាក្យ **final** មានន័យថា ចុងបញ្ចប់ និងចងកាតព្វកិច្ច។

27. ទោះបីជាការប្រើប្រាស់ពាក្យ"final" និង"definitive"មានលក្ខណៈអាចជំនួសគ្នាបាននៅក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា និង អ.វ.ត.ក. ក៏ដោយ ក៏អានុភាពរួមបញ្ចូលគ្នានៃបទប្បញ្ញត្តិទាំងនេះ[65]បានឱ្យឃើញថា នីតិវិធីបណ្តឹងឧទ្ធរណ៍មានអានុភាពបង្អង់សេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូង គឺថា៖ ការអនុវត្តន៍សេចក្តីសម្រេចត្រូវបង្អង់រហូតដល់អំឡុងពេលសម្រាប់បណ្តឹងឧទ្ធរណ៍ត្រូវបានផុតកំណត់ ឬជាជម្រើស រហូតដល់សេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍លើអង្គសេចក្តីត្រូវបានចេញដោយតុលាការបណ្តឹងឧទ្ធរណ៍នោះ។

28. ដោយបានដាក់ឯកសារ និងជូនដំណឹងត្រឹមត្រូវអំពីបណ្តឹងសាទុក្ខ នួន ជា បានបន្តជំហានយ៉ាងសមស្របក្នុងការប្រើប្រាស់សិទ្ធិស្របច្បាប់របស់គាត់ផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ ការធ្វើដូច្នេះ នួន ជា បានចុះក្នុងកំណត់ត្រាបង្ហាញអំពីចេតនារបស់គាត់ថា គាត់បានពិចារណា និងរកឃើញកំហុសអង្គច្បាប់ និង/ឬអង្គហេតុចំនួន ៣៥១ នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

29. ជាក់ច្បាស់ណាស់ នៅចំពោះមុខ អ.វ.ត.ក. នៅពេលពិរុទ្ធជនដាក់បណ្តឹងសាទុក្ខ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពុំទាន់ចូលជាស្ថាពរនៅឡើយ។ អាស្រ័យហេតុនេះ ស្ថានភាពនេះគឺផ្ទុយគ្នាទៅនឹង*រឿងក្តី Delić* និង *Popović* ដែលនៅចំពោះមុខអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY[66]។

30. ក្របខ័ណ្ឌច្បាប់ដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក. តម្រូវឱ្យយល់ឃើញថា ដោយសារ នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ សាលក្រមអង្គជំនុំជម្រះសាលាដំបូងពុំចូលជាស្ថាពរឡើយ។

## គ. ការមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូង

### សារណា

---

[65] *សូមមើល* មាត្រា ១២ ៣៩៨ និង ៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ *សូមមើល* មាត្រា ១១១(៦) នៃវិធានផ្ទៃក្នុង។ មាត្រានេះពុំបានដាក់បញ្ចូលអំពីការផ្តល់សំណងដោយអនុលោមតាមវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុងឡើយ។ *សូមមើលខាងក្រោម* កថាខណ្ឌ ៨៣។

[66] *សូមមើលខាងលើ* កថាខណ្ឌ ២៥។

*មេធាវីការពារក្ដី នួន ជា*

31. ដោយផ្អែកលើការអនុវត្តន៍ក្នុងស្រុករបស់យុត្តាធិការមួយចំនួន មេធាវីការពារក្ដី នួន ជា បានលើកឡើងថា ការស្លាប់របស់ម្ចាស់បណ្ដឹងសាទុក្ខមុនពេលការចេញសាលដីកា បណ្ដាលឱ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខ និង"ជាចាំបាច់ រួមបញ្ចូលការមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូង"។ មេធាវីការពារក្ដីអះអាងថា ការលើកឡើងនេះស្របជាមួយនឹងបទដ្ឋានអន្តរជាតិ[67]។

32. មេធាវីការពារក្ដីបានផ្អែកសំណើរបស់ខ្លួនសុំមោឃៈនេះលើការអានបញ្ចូលគ្នារវាងមាត្រា ៣៦*ថ្មី* នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក.[68] និងវិធាន ១១១(៦) នៃវិធានផ្ទៃក្នុង[69]ក្នុងការសន្និដ្ឋានថា "ដោយហេតុថា ការបញ្ចប់កិច្ចដំណើរការនីតិវិធីពុំមែនជាការសម្រេចបដិសេធបណ្ដឹងសាទុក្ខលើអង្គសេចក្ដី ហើយប្រសិនបើកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ដោយសារមរណភាពនៃម្ចាស់បណ្ដឹងសាទុក្ខ ដូច្នេះសាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវតែចាត់ទុកជាមោឃៈ"[70]។

*សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី*

33. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា ផ្ទុយទៅនឹងការលើកឡើងរបស់មេធាវីការពារក្ដី នួន ជា សាលក្រមអង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានមោឃៈ ហើយកំណត់ត្រានៃការជំនុំជម្រះនៅរក្សាទុកដដែល។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំអង្គជំនុំជម្រះ"មិនឱ្យផ្ដល់អានុភាពលើសេចក្ដីសម្រេច ដែលប៉ះពាល់ដល់តម្លៃជានិមិត្តរូបនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ជាពិសេស ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានផ្ដល់សក្ខីកម្ម"

---

[67] សំណើបន្ទាន់ កថាខណ្ឌ ២០ ដល់ ២៣ និង ៣២ ដល់ ៣៣។

[68] មាត្រា ៣៦*ថ្មី* នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ចែងថា"អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូលជំនុំជម្រះលើបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ របស់ជនរងគ្រោះ និងរបស់សហព្រះរាជអាជ្ញា ពីសាលដីការបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ក្នុងករណីនេះ តុលាការកំពូលពិនិត្យ សម្រេច ជាចុងក្រោយទាំងហេតុ ទាំងអង្គច្បាប់ដោយមិនបង្វិលសំណុំរឿងមកអង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងវិញទេ"។

[69] វិធាន ១១១(៦) នៃវិធានផ្ទៃក្នុងចែងថា "អនុលោមតាមច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលត្រូវព្យាយាមសម្រេចឱ្យបាននូវសម្លេងឯកច្ឆ័ន្ទ។ ប្រសិនបើមិនអាចរកសម្លេងឯកច្ឆ័ន្ទនេះបានទេ សេចក្ដីសម្រេចត្រូវធ្វើឡើងដោយសម្លេងគាំទ្រយ៉ាងហោចណាស់ដោយចៅក្រម ៥(ប្រាំ)សម្លេង។ ក្នុងករណីដែលបណ្ដឹងសាទុក្ខត្រូវបានបដិសេធ នោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវចូលជាស្ថាពរ និងមិនអាចតវ៉ាបានទៀតឡើយ"។

[70] សំណើបន្ទាន់ កថាខណ្ឌ ២២។

និងបានអះអាងថា ការយល់ឃើញដែលថា កំណត់ត្រានៃការជំនុំជម្រះនោះនៅរក្សាដដែល គឺ"ស្របទៅនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការឱ្យមានការបង្ហាញអង្គហេតុ នៅក្នុងសេចក្តីសម្រេចរបស់តុលាការ"[71]។

*សហព្រះរាជអាជ្ញា*

34. សហព្រះរាជអាជ្ញាបានលើកឡើងថា សំអាងផ្លូវច្បាប់របស់ អ.វ.ត.ក. កម្ពុជា និងអន្តរជាតិ ពុំបានគាំទ្រអំណះអំណាងរបស់មេធាវីការពារក្តី នួន ជា ដែលថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងគប្បីត្រូវបានមោឃៈ នៅពេលកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ ត្រូវបានបញ្ចប់បន្ទាប់ពីមរណភាពរបស់ជនជាប់ចោទ។ សហព្រះរាជអាជ្ញាបានបង្ហាញថា បទប្បញ្ញត្តិក្នុងស្រុកដែលមេធាវីបានយោងទៅលើនោះពុំបានគាំទ្រអំណះអំណាងរបស់ខ្លួនពាក់ព័ន្ធបញ្ហានេះឡើយ[72]។

**ការពិចារណា**

35. អំណះអំណាងរបស់មេធាវីការពារក្តី នួន ជា ដែលថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវមោឃភាពនោះ នៅពេលកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់បន្ទាប់ពីមរណភាពរបស់ នួន ជា ពុំមានការគាំទ្រនៅក្នុងច្បាប់កម្ពុជា។ ដូចគ្នាដែរ ពុំមានមាត្រាណាមួយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌកម្ពុជាដែលអនុញ្ញាតការធ្វើមោឃភាពដោយឥតលក្ខខណ្ឌលើសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងដោយគ្មានការពិនិត្យឡើងវិញជាមុនតាមផ្លូវតុលាការឡើយ។

36. ក្របខ័ណ្ឌច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ពុំមានវិធានស្តីពីនីតិវិធីដែលអនុញ្ញាតការធ្វើមោឃភាពសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងកាលៈទេសៈ ដែលកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខត្រូវបានបញ្ចប់បន្ទាប់ពីមរណភាពរបស់ជនជាប់ចោទ។

37. អង្គជំនុំជម្រះយល់ឃើញថា ការធ្វើមោឃភាពសាលក្រមអង្គជំនុំជម្រះសាលាដំបូងនៅពេលជនជាប់ចោទស្លាប់ គឺជាបញ្ហាមូលដ្ឋានដ៏សំខាន់ ប្រសិនបើក្នុងគោលបំណងដូច្នេះមែន ប្រាកដជាមានបទប្បញ្ញត្តិចែងច្បាស់លាស់ទាំងនៅក្នុងច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ទាំងវិធានផ្ទៃក្នុង ឬច្បាប់កម្ពុជា និងប្រាកដជាមានបទប្បញ្ញត្តិច្បាស់លាស់ដូចគ្នានឹងបទប្បញ្ញត្តិស្តីពីការរលត់បណ្តឹងអាជ្ញា ក្រោយពីមរណ

[71] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦ ដល់ ៨។

[72] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦ ដល់ ១៨។

ភាពរបស់ជនជាប់ចោទ ដែលមានចែងដោយឥតព្រលាំក្នុងមាត្រា ៧(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[73] ។ ហេតុដូច្នេះ ការចេញដីកាបង្គាប់ឱ្យមោឃសាលក្រមអង្គជំនុំជម្រះសាលាដំបូង គឺជាជំហានមួយដែលពុំត្រូវបានអនុញ្ញាតដោយច្បាប់ ហើយអាចផ្ទុយទៅនឹងបទដ្ឋានដែលបានបង្កើតឡើងច្បាស់លាស់នៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខនៅ អ.វ.ត.ក. និងតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតដែលចែងថា មិនត្រូវរំខានអ្វីបន្តិចសោះឡើយដល់ការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង[74]។ បន្ថែមលើនេះ ការមោឃភាពកំណត់ត្រាការជំនុំជម្រះទាំងមូល និងការយល់ឃើញបន្ទាប់ពីការអនុវត្តន៍យ៉ាងពេញលេញស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងយុត្តិធម៌ចំពោះជនជាប់ចោទ គឺជាការមិនអើពើទាល់តែសោះទៅលើអត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ។

38. អង្គជំនុំជម្រះពិចារណាឃើញថា មេធាវីការពារក្តីបានបកស្រាយច្របល់ចូលគ្នាមាត្រា ៣៦*ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ជាមួយនឹងវិធាន ១១១(៦) នៃវិធានផ្ទៃក្នុង ក្នុងការសន្និដ្ឋានដោយពុំត្រឹមត្រូវថា "ដោយហេតុថា ការបញ្ចប់កិច្ចដំណើរការនីតិវិធីពុំមែនជាការសម្រេចបដិសេធបណ្តឹងសាទុក្ខលើអង្គសេចក្តី ហើយប្រសិនបើកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ដោយសារមរណភាពនៃម្ចាស់បណ្តឹងសាទុក្ខ ដូច្នេះ សាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវតែចាត់ទុកជាមោឃៈ"[75]។

39. ដូចបានលើកឡើងនៅក្នុងសេចក្តីសម្រេចស្តីពីការបញ្ចប់កិច្ចដំណើរការនីតិវិធី មរណភាពរបស់ នួន ជា បាននាំឱ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ ដែល *ជាក់ស្តែង* បានរលត់ឱកាស

[73] ការយល់ឃើញនេះត្រូវបានគាំទ្របន្ថែមតាមរយៈការអនុវត្តន៍តាមសុភាសិតជាភាសាឡាតាំងពីរឃ្លាស្តីពីការបកស្រាយ និងការបង្កើតលក្ខន្តិកៈ និងលិខិតប្រគល់សិទ្ធិ។ "Expressio unius est exclusio alterius" មានន័យថា សំដៅលើតែអ្វីដែលបានបញ្ជាក់ច្បាស់លាស់ប៉ុណ្ណោះទើបមានអានុភាព ឬមានតែការបញ្ជាក់មួយគត់ដែលមានអានុភាព មិនរាប់បញ្ចូលអ្វីផ្សេងៗទៀតឡើយ និង"expressum facit cessare tacitum អ្វីដែលបានបញ្ជាក់ បានធ្វើឱ្យអ្វីដែលមិនបានបញ្ជាក់ទៅជាគ្មានអានុភាព ឬអានុភាពមានតែលើអ្វីដែលមានចែងច្បាស់លាស់ មិនរាប់បញ្ចូល ឬពាក់ព័ន្ធនឹងបទប្បញ្ញត្តិដទៃទៀតឡើយ។

[74] សាលដីកាសំណុំរឿង ០០១ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ F28 កថាខណ្ឌ ១៧។ សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ F36 កថាខណ្ឌ ៨៨៖"អនុវត្តបទដ្ឋានសមហេតុផលនៅក្នុងការពិនិត្យឡើងវិលើការយល់ឃើញដែលរងការជំទាស់ផ្នែកអង្គហេតុ ពុំមែនបញ្ហាថាតើ ការយល់ឃើញនោះត្រឹមត្រូវ ដែរឬយ៉ាងណានោះទេ។ ក្នុងការកំណត់ថាតើ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងផ្នែកអង្គហេតុ គឺជាការយល់ឃើញដែលពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចផ្តល់បែបនេះ ដែរ ឬយ៉ាងនោះ អង្គជំនុំជម្រះតុលាការកំពូល'នឹងពុំត្រូវរំខានអ្វីសោះឡើយដល់ការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង'"។

[75] សំណើបន្ទាន់ កថាខណ្ឌ ២២។

របស់អង្គជំនុំជម្រះក្នុងការចេញសាលដីកាក្នុងរឿងក្ដីរបស់គាត់[76]។ ហេតុដូច្នេះ វិធាន ១១១(៦) នៃវិធានផ្ទៃក្នុង និងមាត្រា ៣៦ *ថ្មី* នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក. ពុំអាចយកមកប្រើប្រាស់ដើម្បីផ្ដល់អានុភាពដល់ការមោឃភាពលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងបានឡើយ។ ដោយហេតុថា មរណភាពរបស់គាត់បានរារាំងអង្គជំនុំជម្រះក្នុងការចេញសាលដីកាទាក់ទងនឹង នួន ជា ដូចនេះជាធម្មតា ពុំមានន័យថា ការបញ្ចប់កិច្ចដំណើរការនីតិវិធីដោយសារមរណភាពនោះ បាននាំឱ្យសាលក្រមអង្គជំនុំជម្រះសាលាដំបូងទៅជាមោឃៈឡើយ។ អាស្រ័យហេតុនេះ សំណើរបស់មេធាវីការពារក្ដី នួន ជា សុំមោឃភាពសាលក្រមអង្គជំនុំជម្រះសាលាដំបូង ពុំមានមូលដ្ឋានគាំទ្រទាំងស្រុង បើទោះបីជាក្នុងច្បាប់កម្ពុជា ឬច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក. ព្រមទាំងការអនុវត្តន៍នានា។

40. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា អង្គជំនុំជម្រះអាចស្វែងរកសេចក្ដីបំភ្លឺនៃវិធានស្ដីពីនីតិវិធីដែលមាននៅក្នុងកម្រិតអន្តរជាតិ ប្រសិនបើនីតិវិធីជាធរមាននោះ "ពុំបានដោះស្រាយទៅលើបញ្ហាជាក់លាក់ណាមួយ ឬប្រសិនបើពុំមានភាពជាក់លាក់ពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍ ឬប្រសិនបើមានភាពមិនស្របគ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ"[77]។ ដូចមានចែងច្បាស់លាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាអំពីប្រព័ន្ធនៃការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខ ហើយពុំបានចែងអំពីមោឃភាពលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដូចនេះពុំឃើញមានភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងការអនុវត្តន៍បទប្បញ្ញត្តិទាំងនេះ អាស្រ័យហេតុនេះ ពុំចាំបាច់មានការស្វែងរកការបំភ្លឺអំពី"វិធានស្ដីពីនីតិវិធីនៅក្នុងកម្រិតអន្តរជាតិ"ឡើយ។

41. ទោះបីជាយ៉ាងណាក្ដី ដោយសារមេធាវីការពារក្ដី នួន ជា បានអះអាងម្ដងហើយម្ដងទៀតថា ការមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូង គឺស្របទៅនឹងបទដ្ឋានអន្តរជាតិ[78] អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យលើឯកសារសំអាងផ្លូវបានច្បាប់ដែលយោងមកជាមួយនោះ។ ផ្អែកតាមការអនុវត្តជាច្រើនរបស់តុលាការព្រហ្មទណ្ឌដែលមានកម្រិតអន្តរជាតិផ្សេងៗឃើញថា អង្គជំនុំជម្រះឧទ្ធរណ៍គោរពតាមតុលាការអង្គហេតុក្នុងការវាយតម្លៃលើភស្តុតាង និងសេចក្ដីសន្និដ្ឋានផ្នែកអង្គហេតុដែលបានធ្វើឡើងតាមរយៈ

---

[76] សេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៨។

[77] មាត្រា ៣៣ *ថ្មី* ៣៧ *ថ្មី* នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក.។

[78] *សូមមើលឧ.* សំណើបន្ទាន់ កថាខណ្ឌ ៣២ ដល់ ៣៣ (ជាពិសេសជើងទំព័រ ៣៧ ដែលយោងទៅលើសច្ចធារណ៍និរទោសតាមច្បាប់បារាំង និងក្រមនីតិវិធីព្រហ្មទណ្ឌអ៊ីតាលី បូស្នី ពាក់ព័ន្ធនឹងសាលក្រមស្ពាពរ) និងកថាខណ្ឌ ៤៥ ដល់ ៤៧ (យោងទៅលើសច្ចធារណ៍និរទោសនៅ អ.វ.ត.ក.)។

ភស្តុតាង ហើយមិនត្រូវរំខានអ្វីសោះឡើយទៅលើការយល់ឃើញនោះ[79]។ អង្គជំនុំជម្រះរកពុំឃើញរឿងក្តីណាមួយដែលគាំទ្រការអនុវត្តន៍មោឃភាពសាលក្រមអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីម្ចាស់បណ្តឹងសាទុក្ខបានស្លាប់។

42. ក្នុងចំណោមសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះឃើញថា មានតែ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Delić និង*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Popović និងអ្នកដទៃទៀត* ប៉ុណ្ណោះ ដែលជាប់ពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃរឿងក្តីបច្ចុប្បន្ន[80]។ រឿងក្តីទាំងពីរនេះពុំបានគាំទ្រការលើកឡើងរបស់មេធាវីការពារក្តី នួន ជា ដែលថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវចាត់ទុកមោឃៈឡើយ។ ផ្ទុយទៅ

[79] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karadžić* សំណុំរឿងលេខ MICT-13-55-A សាលដីកា អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៩ កថាខណ្ឌ ១៧។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Šešelj* សំណុំរឿងលេខ MICT-16-99-A សាលដីកា អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៨ កថាខណ្ឌ ១៥។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Ngirabatware* សំណុំរឿងលេខ MICT-12-29-A សាលដីកា អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១០។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Prlić និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-04-74-A សាលដីកា អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៧ កថាខណ្ឌ ២២។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Stanišić និង Župljanin* សំណុំរឿងលេខ IT-08-91-A សាលដីកា អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ២១។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Nyiramasuhuko និងអ្នកដទៃទៀត* សំណុំរឿងលេខ ICTR-98-42-A សាលដីកា អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៣២។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Taylor* សំណុំរឿងលេខ SCSL-03-01-A សាលដីកា អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦។

[80] សេចក្តីសម្រេច*រឿងក្តី Gvero* កថាខណ្ឌ ៦ ("អង្គជំនុំជម្រះឧទ្ធរណ៍ពិចារណាឃើញថា បន្ទាប់ពីបានរកឃើញថា មរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខបណ្តាលឱ្យបញ្ចប់កិច្ចដំណើរការនីតិវិធី និងដោយសារពុំមានសាលដីកាលើបណ្តឹងសាទុក្ខត្រូវបានចេញពាក់ព័ន្ធនឹង Gvero ពុំមានអ្វីអាចប៉ះពាល់ដល់ការចូលស្ថាពរនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលពាក់ព័ន្ធនឹង Gvero ឡើយ។ ជាលទ្ធផល សាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវចាត់ទុកជាស្ថាពរទាក់ទងទៅនឹង Gvero")។ សេចក្តីសម្រេច*រឿងក្តី Delić* កថាខណ្ឌ ១៥ ("បន្ទាប់ពីបានរកឃើញថា មរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខបណ្តាលឱ្យបញ្ចប់កិច្ចដំណើរការនីតិវិធី និងដោយសារពុំមានសាលដីកាលើបណ្តឹងសាទុក្ខត្រូវបានចេញពាក់ព័ន្ធនឹងរឿងក្តីនេះ ពុំមានអ្វីអាចប៉ះពាល់ដល់ការចូលជាស្ថាពរនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងនេះឡើយ។ ជាលទ្ធផល សាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវចាត់ទុកជាស្ថាពរ")។ នៅក្នុងករណីនីមួយៗ ម្ចាស់បណ្តឹងសាទុក្ខបានស្លាប់បន្ទាប់ពីដាក់សារណានៅដំណាក់កាលបណ្តឹងសាទុក្ខ។ ដូចបានលើកឡើងនៅក្នុងផ្នែកនៃការចូលជាស្ថាពរ សេចក្តីសម្រេច*រឿងក្តី Delić* កថាខណ្ឌ ១៤ ដល់ ១៥ និង សេចក្តីសម្រេច *រឿងក្តី Gvero* កថាខណ្ឌ ៦ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះឧទ្ធរណ៍បានបញ្ចប់កិច្ចដំណើរការនីតិវិធីលើម្ចាស់បណ្តឹងឧទ្ធរណ៍បន្ទាប់ពីមរណភាព ប៉ុន្តែបានសម្រេចថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវតែចាត់ថា ស្ថាពរ ក្នុងរឿងក្តីនីមួយៗ។

វិញ អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY បានពិចារណានៅក្នុងរឿងក្ដីទាំងពីរនេះថា "វិធីសាស្ត្រដែលអនុវត្តតាមនៅក្នុងយុត្តិសាស្ត្រក្នុងស្រុកមួយចំនួន ក្នុងករណីការដាក់ពិរុទ្ធភាពដែលត្រូវបានសម្រេចដោយតុលាការជាន់ដំបូងត្រូវបានមោឃៈក្រោយពេលមរណភាពម្ចាស់បណ្ដឹងសាទុក្ខនោះ ពុំស្របជាមួយនឹងសារៈសំខាន់នៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខ"នៅចំពោះមុខតុលាការ ICTY[81]។

43. បើទោះបីជាអង្គជំនុំជម្រះ បានរកឃើញមូលហេតុក្នុងការងាកចេញពីសេចក្ដីសន្និដ្ឋានដែលបានធ្វើឡើងដោយអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY ក្នុង*រឿងក្ដី Delić* និង*រឿងក្ដី Popović និងជនដទៃទៀត* ពាក់ព័ន្ធទៅនឹងការចូលជាស្ថាពរនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងក៏ដោយ[82] ក៏ផ្នែកខ្លះនៃសាលក្រមពាក់ព័ន្ធទៅនឹងការមោឃភាព និងការលុបចោលទាំងស្រុងនោះ នៅតែបង្ហាញឱ្យដឹងថា អង្គជំនុំជម្រះឧទ្ធរណ៍ក្នុង*រឿងក្ដី Delić* បានពិនិត្យលើទឡ្ហីករណ៍ប្រហាក់ប្រហែលគ្នាទៅនឹងអ្វីដែលមេធាវីការពារក្ដីបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណើសុំបន្ទាន់នេះ។ អង្គជំនុំជម្រះឧទ្ធរណ៍បានពិនិត្យលើវិធីសាស្ត្ររបស់យុត្តាធិការនៃប្រព័ន្ធច្បាប់ស៊ីវិល និងអង់គ្លូសាក់សុងចំពោះបញ្ហាដូចគ្នានេះ ប៉ុន្តែពុំអាចរកការ "បំភ្លឺបន្ថែមអំពីវិធីសាស្ត្រទូទៅណាមួយនោះទេ កុំថាឡើយរហូតដល់ទៅអាចស្វែងរកបាននូវវិធាននានានៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលអាចអនុវត្តបានដោយផ្ទាល់" ក្រោយពេលមរណភាពរបស់ម្ចាស់បណ្ដឹងសាទុក្ខនោះ[83]។ អង្គជំនុំជម្រះយល់ស្របជាមួយនឹងសេចក្ដីសន្និដ្ឋាននេះ។

44. បើទោះបីជាពុំបានផ្ដល់មូលហេតុច្បាស់លាស់ ឬអំណះអំណាងនៅក្នុងសំណើសុំបន្ទាន់ក៏ដោយ[84] ការសំអាងផ្លូវច្បាប់តែមួយគត់ ដែលទំនងជាគាំទ្រជំហរមេធាវីការពារក្ដីពាក់ព័ន្ធទៅនឹងមោឃភាពសាលក្រមអង្គជំនុំជម្រះសាលាដំបូងនោះ គឺជាគោលការណ៍ច្បាប់អង់គ្លូសាក់សុងស្ដីពីការលុបចោល*ចាប់តាំងពីដំណាក់កាលដំបូង (ab initio)* ដែលបានយោងនៅក្នុងជើងទំព័រពាក់ព័ន្ធទៅនឹងការបញ្ចប់កិច្ចដំណើរការ

---

[81] សេចក្ដីសម្រេច*រឿងក្ដី Delić* កថាខណ្ឌ ១៤។ សេចក្ដីសម្រេច*រឿងក្ដី Gvero* កថាខណ្ឌ ៦ (សេចក្ដីបញ្ជាក់បន្ថែម)។

[82] សេចក្ដីសម្រេច*រឿងក្ដី Delić* កថាខណ្ឌ ១៤។ សេចក្ដីសម្រេច*រឿងក្ដី Gvero* កថាខណ្ឌ ៦ (សេចក្ដីបញ្ជាក់បន្ថែម)។

[83] សេចក្ដីសម្រេច*រឿងក្ដី Delić* កថាខណ្ឌ ១៣។

[84] សំណើបន្ទាន់ កថាខណ្ឌ ៣២។ *សូមមើលផងដែរ* កថាខណ្ឌ ១(ខ)(i), ២២ ដល់ ២៣, ២៩(ខ)(i)។ ពុំមានសំអាងផ្លូវច្បាប់ត្រឹមត្រូវត្រូវបានបង្ហាញនៅក្នុងសារណារបស់មេធាវីការពារក្ដីដែលគាំទ្រអំណះអំណាងរបស់ខ្លួនដែលថា ការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខជាស្វ័យប្រវត្តិមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ មាត្រាបឋម មាត្រា ៦ និង ៣២៧(៤) នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។ មាត្រា ៦៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌអ៊ីតាលី និងមាត្រា ២៩(២) នៃរដ្ឋធម្មនុញ្ញសាធារណៈរដ្ឋអ៊ីតាលី។ មាត្រា ៣ និង ១៧៨(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌរុស្ស៊ី។

នីតិវិធីដែលថា៖ "នៅក្នុងសហរដ្ឋអាមេរិក តុលាការភាគច្រើន រួមមានតុលាការសហព័ន្ធស្ទើរតែទាំងអស់ បានអនុវត្តតាមគោលការណ៍ស្តីពីការលុបចោល *ចាប់តាំងពីដំណាក់កាលដំបូង (ab initio)* នៃការដាក់ពិរុទ្ធ ដែលត្រូវលុបចោលរាល់ភស្តុតាងទាំងអស់ដែលមាននៅក្នុងនោះ"[85]។ តាមការពិនិត្យនៅក្នុង *រឿងក្តី Delić*[86] អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា គោលការណ៍នេះកើតចេញពីតម្រូវការបន្ទាន់នៃនីតិវិធីព្រហ្មទណ្ឌសតវត្សទីដប់ប្រាំបួន ហើយការអនុវត្តន៍នៃគោលការណ៍នេះពុំទាន់បានទូលំទូលាយចំពោះយុត្តាធិការទាំងអស់របស់សហរដ្ឋអាមេរិក[87]។ នៅគ្រប់កាលៈទេសៈ គោលការណ៍ស្តីពីការលុបចោល *ចាប់តាំងពីដំណាក់កាលដំបូង (ab initio)* ពុំត្រូវបានទទួលស្គាល់ចំពោះប្រព័ន្ធច្បាប់ស៊ីវិលដែលជាមូលដ្ឋាននៃច្បាប់កម្ពុជា ហើយ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានមូលហេតុណាមួយត្រូវអនុវត្តតាមគោលការណ៍នេះឡើយ។

---

[85] សំណើបន្ទាន់ ជើងទំព័រ ២៥។

[86] សេចក្តីសម្រេច *រឿងក្តី* Delić កថាខណ្ឌ ១២ និងជើងទំព័រ ៣៥៖ "ក្នុងសហរដ្ឋអាមេរិក តុលាការឧទ្ធរណ៍នៃសហព័ន្ធជាទូទៅបានអនុម័តវិធិសាស្ត្រដែលក្នុងរឿក្តីនោះ កិច្ចដំណើរការនីតិវិធីបញ្ចប់ *ចាប់តាំងពីដំណាក់ដំបូង* បណ្តាលឱ្យការសម្រេចដាក់ពិរុទ្ធភាពទៅជាមោឃៈ និងដីកាសម្រេចចោទប្រកាន់គ្មានសុពលភាព"។

[87] *សូមមើលជាឧទាហរណ៍ថ្មីៗ៖ រឿងក្តី* Commonwealth *ទល់នឹង* *Aaron J. Hernandez* តុលាការជាន់ខ្ពស់រដ្ឋ Massachussetts ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៩ ទំព័រ ២៩៖ "ដោយសារយើងពុំអាចរកបាននូវការវិភាគសមហេតុផលសម្រាប់អនុវត្តតាមគោលការណ៍ដែលលបចោលទាំងអស់តាំងពីដំណាក់កាលដំបូង និងនៅគ្រប់កាលៈទេសៈ យើងទទួលបានសំអាងហេតុលើអង្គសេចក្តីដែលគប្បីត្រូវកែប្រែ យើងសន្និដ្ឋានថា យើងលែងអនុវត្តតាមគោលការណ៍នេះតទៅទៀត នៅពេលចុងចោទបានស្លាប់ក្នុងអំឡុងពេលរង់ចាំបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដែលជាសិទ្ធិជំទាស់ទៅនឹងការសម្រេចដាក់ពិរុទ្ធភាព។ ជំនួសវិញ ក្រោយពេលមរណភាពរបស់ចុងចោទ បណ្តឹងឧទ្ធរណ៍ត្រូវបានច្រានចោលជាអសារបង់ ហើយអង្គជំនុំជម្រះសាលាដំបូងត្រូវបានណែនាំរក្សាកំណត់ត្រាទុកថា ពិរុទ្ធភាពរបស់ចុងចោទបានដកការសន្មតថាឥតទោសចេញពីចុងចោទ ប៉ុន្តែថា ពិរុទ្ធភាពនេះត្រូវបានប្តឹងឧទ្ធរណ៍ និងពុំត្រូវបានតម្កល់ ឬបដិសេធនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ ពីព្រោះចុងចោទបានស្លាប់ខណៈពេលរង់ចាំបណ្តឹងឧទ្ធរណ៍ ហើយបណ្តឹងឧទ្ធរណ៍ត្រូវបានច្រានចោល"។ *សូមមើល*អត្ថបទរបស់ Bierer, S. M. ចំណងជើង "សារៈសំខាន់នៃការទទួលផលចំណេញ៖ ថាតើការលុបចោលក្រោយមរណភាពបានប៉ះពាល់ជាប្រតិភោគដល់អ្នកធានារ៉ាប់រង គ្រួសារ និងសង្គមទាំងមូល ដែរ ឬយ៉ាងណា"(ឆ្នាំ ២០១៣) លេខ ៧៨ បញ្ហាទី ៤ ការពិនិត្យឡើងវិញផ្នែកច្បាប់នៅសង្កាត់ Brooklyn។ អត្ថបទរបស់ Razel, T. A. ចំណងជើង"ស្លាប់ដើម្បីបញ្ចៀសការដាក់ទោស៖ ថាតើគោលការណ៍លុបចោល ពុំអាចធ្វើឱ្យទទួលបានយុត្តិធម៌ ដែរ ឬយ៉ាងណា និងតើគួរធ្វើអ្វីជំនួសវិញ"(ឆ្នាំ ២០០៧) លេខ ៧៥ បញ្ហាទី ៤ ការពិនិត្យឡើងវិញផ្នែកច្បាប់នៅសាកលវិទ្យាល័យ Fordham។

45. អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានហេតុផលណាមួយតម្រូវឱ្យមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុនេះកំណត់ត្រាពេញលេញនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវចាត់ទុកជាបានការ។

## ឃ. សច្ចធារណ៍និរទោស

### សារណា

*មេធាវីការពារក្ដី នួន ជា*

46. មេធាវីការពារក្ដី នួន ជា បានលើកឡើងថា ការបកស្រាយបញ្ចូលគ្នារវាងមាត្រា ៣៥*ថ្មី* ៣៦*ថ្មី* និង ៣៧*ថ្មី* នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក. រួមទាំងវិធាន ១១១(៦) នៃវិធានផ្ទៃក្នុងឃើញថា សច្ចធារណ៍និរទោសបន្តមានអត្ថិភាពនៅដំណាក់កាលបណ្ដឹងសាទុក្ខបន្ទាប់ពីការសម្រេចដាក់ពិរុទ្ធភាពដែលរង់ចាំសាលដីកាពីអង្គជំនុំជម្រះតុលាការកំពូល[88]។ មេធាវីការពារក្ដីបានទទូចសុំឱ្យអង្គជំនុំជម្រះសម្រេចថា "ប្រសិនបើកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខត្រូវបានបញ្ចប់ដោយសារមរណភាពរបស់ម្ចាស់បណ្ដឹងសាទុក្ខ" ដូច្នេះ អង្គជំនុំជម្រះមានជម្រើសតែមួយគត់ គឺមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើមូលដ្ឋានថា សច្ចធារណ៍និរទោសមានអត្ថិភាពនៅដំណាក់កាលបណ្ដឹងសាទុក្ខ[89]។

47. មេធាវីការពារក្ដីបានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY ក្នុង*រឿងក្ដី* Delić មានកំហុសដែលថា "សច្ចធារណ៍និរទោសពុំត្រូវអនុវត្តចំពោះបុគ្គលដែលត្រូវបានសម្រេចដាក់ពិរុទ្ធភាព ដោយអង្គជំនុំជម្រះសាលាដំបូង ដោយរង់ចាំសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ខ្លួន"[90] និងថា នៅគ្រប់ករណីទាំងអស់ សេចក្ដីសម្រេចក្នុង*រឿងក្ដី* Delić មិនអាចអនុវត្តបានដោយផ្អែកលើបទប្បញ្ញត្តិនៃក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.[91]ដែល"នាំឱ្យធ្វើការសន្និដ្ឋានបានថា សច្ចធារណ៍និរទោសមានអត្ថិភាពនៅដំណាក់កាលបណ្ដឹងសាទុក្ខ"[92]។

---

[88] សំណើបន្ទាន់ កថាខណ្ឌ ៣២ ដល់ ៤៧។

[89] សំណើបន្ទាន់ កថាខណ្ឌ ២២ ដល់ ២៣។

[90] សំណើបន្ទាន់ កថាខណ្ឌ ៣៧ ដល់ ៤៣។ សេចក្ដីសម្រេច *រឿងក្ដី Delić* កថាខណ្ឌ ១៤។

[91] មាត្រ ៣៥ *ថ្មី* ៣៦ *ថ្មី* ៣៧ *ថ្មី*នៃច្បាប់ស្ដីពីការបង្កើឱ្យមាន អ.វ.ត.ក. និងធាន ១១១(៦) នៃវិធានផ្ទៃក្នុង។

[92] សំណើបន្ទាន់ កថាខណ្ឌ ៤៥។

*សហព្រះរាជអាជ្ញា*

48. សហព្រះរាជអាជ្ញាបានលើកឡើងថា ដោយហេតុថា រដ្ឋធម្មនុញ្ញកម្ពុជា"ចែងអំពីសច្ចធារណ៍និរទោសមានអត្ថិភាពរហូតដល់សាលក្រមស្ថាពរ" វចនាសម្ព័ន្ធ អាណត្តិ យុត្តាធិការ និងអត្តចរិតរបស់ អ.វ.ត.ក. មានលក្ខណៈខុសប្លែកពីផ្នែកដទៃទៀតនៃប្រព័ន្ធតុលាការកម្ពុជា[93]។ សហព្រះរាជអាជ្ញាអះអាងថា "ភាពខុសប្លែកគ្នាទាំងស្រុងនេះ"[94] ប្រើជាមូលដ្ឋានសម្រាប់"ជនជាប់ចោទដែលត្រូវតែបានសន្មតថាឥតទោសនៅ អ.វ.ត.ក. ដរាបណាពិរុទ្ធភាពពុំត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យដោយតុលាការអង្គហេតុ"[95]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា មាត្រា ២៥ និង ៣៧ *ថ្មី*នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ពុំស្របគ្នាជាមួយនឹងនីតិវិធី និងការអនុវត្តន៍ពាក់ព័ន្ធនៅកម្រិតអន្តរជាតិ និងថា ផ្អែកតាមមូលដ្ឋាននេះ ការបំភ្លឺគប្បីស្វែងនៅក្នុងវិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ[96]។

49. សហព្រះរាជអាជ្ញាអះអាងថា ភាពស្រដៀងគ្នានៃវចនាសម្ព័ន្ធបណ្តឹងសាទុក្ខ និងបទដ្ឋាននៃការពិនិត្យឡើងវិញរវាង អ.វ.ត.ក. និងតុលាការព្រហ្មទណ្ឌកម្រិតអន្តរជាតិ បានធ្វើឱ្យការអនុវត្តរបស់តុលាការនេះមាន"លក្ខណៈពាក់ព័ន្ធយ៉ាងពិសេស"[97]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាយល់ស្របទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY ក្នុង*រឿងក្តី Delić* ដែលថា "សច្ចធារណ៍និរទោសពុំត្រូវអនុវត្តចំពោះបុគ្គល ដែលត្រូវបានសម្រេចដាក់ពិរុទ្ធភាពដោយអង្គជំនុំជម្រះសាលាដំបូងហើយកំពុងរង់ចាំដំណោះស្រាយលើបណ្តឹងសាទុក្ខរបស់ខ្លួននោះ"[98]។ សហព្រះរាជអាជ្ញាបានយល់ស្របទៅលើសំអាងហេតុដែលថា បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ និងបន្ទុកភស្តុតាងលើបណ្តឹង

---

[93] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ សាលដីកាសំណុំរឿង ០០២/០១ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ F36 កថាខណ្ឌ ១០៧។ សាលដីកាសំណុំរឿង ០០១ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ F28 កថាខណ្ឌ ៣៥៨។

[94] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

[95] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

[96] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤ ដល់ ៥។

[97] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦ ដល់ ៧។

[98] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨ *យោងទៅលើ*សេចក្តីសម្រេច *រឿងក្តី Delić* កថាខណ្ឌ ១៤។

សាទុក្ខ"គឺខុសប្លែកគ្នាយ៉ាងជាក់ច្បាស់រវាងបទដ្ឋានដែលអនុវត្តនៅដំណាក់កាលជំនុំជម្រះ ដែលសច្ចធារណ៍និរទោសមានអត្ថិភាព ហើយអយ្យការត្រូវតែបង្ហាញភស្តុតាងលើរឿងក្តីឱ្យហួសពីវិមតិសង្ស័យ"[99]។

50. យោងតាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា ការប្រកាសថា នួន ជា គួរតែបន្តសន្មតថាគ្មានទោស បើទោះបី ជាមានការសម្រេចដាក់ពិរុទ្ធភាពក៏ដោយនោះបន្ទាប់ពីការជំនុំជម្រះត្រូវបានធ្វើឡើងដោយមានការធានាបាននូវដំណើរការនីតិវិធីទាំងអស់ និងការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ នួន ជា ក្នុងនាមជាជនជាប់ចោទ អាចនឹងប៉ះពាល់ដល់គោលបំណងក្នុងការបង្កើតតុលាការនេះ និងប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះ[100]។

*សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី*

51. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលត្រូវបានចាត់ទុកពុំមែនស្ថាពរនោះ គ្មានអានុភាពផ្លូវច្បាប់លើមរណជន។ សហមេធាវីបានសន្និដ្ឋានថា ការយល់ឃើញនេះគឺស្របជាមួយនឹងគោលការណ៍សច្ចធារណ៍និរទោស[101]។

*មេធាវីការពារក្តី ខៀវ សំផន*

52. *មេធាវីការពារក្តី* ខៀវ សំផន បានលើកឡើងថា "ច្បាប់កម្ពុជា និងច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ចែងច្បាស់លាស់ថា សច្ចធារណ៍និរទោសបន្តអនុវត្តនៅដំណាក់កាលបណ្តឹងសាទុក្ខ"[102]។ អាស្រ័យហេតុនេះ នៅពេលម្ចាស់បណ្តឹងសាទុក្ខបានស្លាប់ នៅមុនពេលការចេញសាលដីកាលើបណ្តឹងសាទុក្ខ ម្ចាស់បណ្តឹងសាទុក្ខ"ស្លាប់ដោយសន្មតថាឥតទោស"[103]។

**ច្បាប់ជាធរមាន**

---

[99] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨ ដល់ ៩ *យោងទៅលើ*សេចក្តីសម្រេច*រឿងក្តី Delić* កថាខណ្ឌ ១៤។

[100] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០ ដល់ ១៥។

[101] សារណាតបរបស់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦។

[102] ការឆ្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៦ ដល់ ២៦ និង ៤៤។

[103] ការឆ្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៦ និង ៤៥។

53. រដ្ឋធម្មនុញ្ញរបស់កម្ពុជាចែងថា “ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ”[104]។ មាត្រា ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលបានចម្លងចូលដោយផ្ទាល់នៅក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. តាមរយៈកិច្ចព្រមព្រៀង[105] និងច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក.[106] បានចែងថា “ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់”។ និយមន័យស្រដៀងគ្នានៃសច្ចធារណ៍និរទោសមានចែងនៅក្នុងវិធានផ្ទៃក្នុង[107]។

54. មាត្រា ៣៥ *ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. បានអនុម័តតាមនិយមន័យដែលថា “ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ”។ មាត្រា ៣៥ *ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ចែងថា មាត្រា ៣៥ *ថ្មី* ត្រូវអនុវត្ត“ដូចគ្នាចំពោះការជំនុំជម្រះក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល”។

55. វិធានផ្ទៃក្នុងចែងថា “ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជន

---

[104] មាត្រា ៣៨(៧) នៃរដ្ឋធម្មនុញ្ញកម្ពុជា។

[105] មាត្រា ១២(២) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាចែងថា “អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ”។ មាត្រា ១៣(១) ចែងថា សិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ត្រូវតែគោរពនៅទូទាំងដំណើរការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេស រួមមានសិទ្ធិទទួលបានសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថា គ្មានទោសពៃរ៍រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង សិទ្ធិមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការការពារខ្លួន សិទ្ធិទទួលបាននូវមេធាវី ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និងសិទ្ធិពិនិត្យ ឬបានពិនិត្យសាក្សីដាក់បន្ទុក។

[106] មាត្រា ៣៣ *ថ្មី*នៃច្បាប់ពីការបង្កើតឱ្យមាន អ.វ.ត.ក. ចែងថា “អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ”។

[107] វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងចែងថា៖ “ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថា គ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ”។

សង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព”[108]។

## ការពិចារណា

56. អង្គជំនុំជម្រះបដិសេធលើអំណះអំណាងរបស់មេធាវីការពារក្ដី នួន ជា ដែលថា អានុភាពនៃសច្ចធារណ៍និរទោសនៅដំណាក់កាលបណ្ដឹងសាទុក្ខ បាននាំឱ្យមានការមោឃភាពសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្ដីបានធ្វើការសន្និដ្ឋានដោយពុំត្រឹមត្រូវ និងបានច្របល់ចូលគ្នារវាងបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក.[109] និងវិធានផ្ទៃក្នុង[110]។

57. អង្គជំនុំជម្រះសង្កេតឃើញថា បទប្បញ្ញត្តិផ្សេងៗនៅក្នុងក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក. ប្រើប្រាស់ពាក្យពេចន៍ខុសប្លែកគ្នាក្នុងការផ្ដល់និយមន័យលើចំណុចដែលសច្ចធារណ៍និរទោសត្រូវអនុវត្ត ឬត្រូវបញ្ចប់។ បើទោះបីជាមេធាវីការពារក្ដីខកខានក្នុងការលើកឡើងក៏ដោយ ក៏រដ្ឋធម្មនុញ្ញកម្ពុជាបានចែងយ៉ាងច្បាស់ថា សច្ចធារណ៍និរទោសត្រូវតែអនុវត្ត“ដរាបណាតុលាការមិនទាន់កាត់ទោស *ជាស្ថាពរ*(**finally**)”[111] ហើយច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក. ចែងថា សច្ចធារណ៍និរទោសមានអត្ថិភាព“ដរាបណាតុលាការមិនទាន់កាត់ទោស*ជាស្ថាពរ*(definitive)”[112]។ ម្យ៉ាងវិញទៀត សច្ចធារណ៍និរទោសមានអត្ថិភាព“រហូតដល់ពិរុទ្ធភាពត្រូវបានបង្ហាញ” នៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[113]

---

[108] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[109] មាត្រា ៣៥ *ថ្មី* ៣៦ *ថ្មី* និង ៣៧ *ថ្មី* នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។

[110] វិធាន ១១១(៦) នៃវិធានផ្ទៃក្នុងចែងថា៖ “អនុលោមតាមច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលត្រូវ ព្យាយាមសម្រេចឱ្យបាននូវសម្លេងឯកច្ឆ័ន្ទ។ ប្រសិនបើមិនអាចរកសម្លេងឯកច្ឆ័ន្ទនេះបានទេ សេចក្ដីសម្រេចត្រូវធ្វើឡើងដោយសម្លេងគាំទ្រយ៉ាងហោចណាស់ដោយចៅក្រម ៥(ប្រាំ)សម្លេង។ ក្នុងករណីដែលបណ្ដឹងសាទុក្ខត្រូវបានបដិសេធ នោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវចូលជាស្ថាពរ និងមិនអាចតវ៉ាបានទៀតឡើយ”។

[111] មាត្រា ៣៨(៧) នៃរដ្ឋធម្មនុញ្ញកម្ពុជា។

[112] មាត្រា ៣៥ *ថ្មី* នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក. ។

[113] មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង។

“ដរាបណាពិរុទ្ធភាពពុំត្រូវបានបង្ហាញ នៅក្នុងវិធានផ្ទៃក្នុង”[114] និង“ដរាបណាពិរុទ្ធភាពត្រូវបានបង្ហាញអនុលោមតាមច្បាប់”នៅក្នុងកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[115]។

58. ដូចបានបង្ហាញនៅក្នុងសារណារបស់ភាគី ភាពខុសប្លែកគ្នានៃនិយមន័យទាំងនេះបណ្ដាលឱ្យមានភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងការបកស្រាយស្ដីពីវិសាលភាពនៃការអនុវត្តន៍ស្ដីពីគោលការណ៍សច្ចធារណ៍និរទោសនៅក្នុងស្ថានភាពដែលម្ចាស់បណ្ដឹងសាទុក្ខបានស្លាប់ នៅមុនពេលការចេញសាលដីកាលើបណ្ដឹងសាទុក្ខ។ ផ្អែកតាមភាពពុំជាក់លាក់ដែលគួបផ្សំជាមួយនឹងចរិតលក្ខណៈថ្មីនៃបញ្ហាជាក់លាក់នៅ អ.វ.ត.ក. និងនៅកម្រិតអន្តរជាតិ អង្គជំនុំជម្រះចាត់ទុកទាំងអស់នេះមានអត្ថប្រយោជន៍ក្នុងការពិភាក្សាអំពីការណែនាំនៅក្នុងវិធានស្ដីពីនីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ[116]។

59. ដូចបានបញ្ជាក់ខាងលើ[117] អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY បានពិចារណាលើភាពអាចអនុវត្តបាននៃសច្ចធារណ៍និរទោសចំពោះម្ចាស់បណ្ដឹងសាទុក្ខ ដែលត្រូវបានសម្រេចដាក់ពិរុទ្ធភាពនៅដំណាក់កាលជំនុំជម្រះ និងបានស្លាប់នៅមុនពេលការចេញសាលដីកាលើបណ្ដឹងសាទុក្ខ[118]។ ក្នុង*រឿងក្ដី Delić* អង្គជំនុំជម្រះបានរកឃើញថា៖

> “សច្ចធារណ៍និរទោសពុំអនុវត្តចំពោះបុគ្គលដែលត្រូវបានសម្រេចដាក់ពិរុទ្ធភាពដោយអង្គជំនុំជម្រះសាលាដំបូង និងកំពុងរង់ចាំដំណោះស្រាយលើបណ្ដឹងសាទុក្ខរបស់ខ្លួន។ ការបកស្រាយបែបនេះ

---

[114] វិធាន ២១(១)(ឃ) វិធានផ្ទៃក្នុង។

[115] មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយត្រូវបានចម្លងចូលទៅក្នុងមាត្រា ១២(២) នៃកិច្ចព្រមព្រៀង និងមាត្រា ៣៣ នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក.។

[116] មាត្រា ១២(១) នៃកិច្ចព្រមព្រៀង៖ “នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ នៅពេលដែលច្បាប់កម្ពុជាពុំអាចដោះស្រាយចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រា ឬការអនុវត្តន៍បទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ”។ មាត្រា ៣៣ *ថ្មី*នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក. “ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះ ជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ”។

[117] *សូមមើលខាងលើ* កថាខណ្ឌ ២៥។

[118] សេចក្ដីសម្រេច*រឿងក្ដី Delić* កថាខណ្ឌ ៩ ១៤ ដល់ ១៥ និង សេចក្ដីសម្រេច*រឿងក្ដី Gvero* កថាខណ្ឌ ៦។

មានលក្ខណៈសមស្របទៅនឹងបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខជាធរមាននៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ ករណីដែលភាគីបណ្តឹងសាទុក្ខមានបន្ទុកក្នុងការបង្ហាញអំពីកំហុសអង្គច្បាប់ ឬអង្គហេតុដែលនាំអោយមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូង ឬនាំឱ្យមានភាពមិនយុត្តិធម៌ ជាជាងការប៉ុនប៉ងផ្តួចផ្តើមការជំនុំជម្រះ*សាឡើងវិញ*។ បន្ទុកនេះមានលក្ខណៈខុសប្លែកគ្នាយ៉ាងជាក់ច្បាស់ពីបន្ទុកដែលអនុវត្តនៅដំណាក់កាលជំនុំជម្រះ ដែលសច្ចធារណ៍និរទោសមានអត្ថិភាព ហើយអយ្យការត្រូវបង្ហាញរឿងក្តីឱ្យហួសពីវិមតិសង្ស័យ”[119]។

60. អង្គជំនុំជម្រះទទួលស្គាល់ថា ភាពស្រដៀងគ្នារវាង អ.វ.ត.ក. និងតុលាការ ICTY ដូចជារចនាសម្ព័ន្ធបណ្តឹងសាទុក្ខ បទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ និងអាណត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងការនាំយកអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោសចំពោះអំពើឃោរឃៅព្រៃផ្សៃដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងអតីតប្រទេសយូហ្គោស្លាវី។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នៅតុលាការ ICTY សច្ចធារណ៍និរទោសត្រូវបានកំណត់យ៉ាងដាច់ដោយឡែកដោយលក្ខន្តិកៈដែលចែងថា “ជនជាប់ចោទត្រូវតែសន្មតថាឥតទោស ដរាបណាពិរុទ្ធភាពពុំត្រូវបានបង្ហាញដោយអនុលោមតាមបទប្បញ្ញត្តិនៃលក្ខន្តិកៈបច្ចុប្បន្ន”[120]។ ចំណុចនេះខុសប្លែកពីក្របខ័ណ្ឌច្បាប់ជាធរមាននៅ អ.វ.ត.ក. ដែលសច្ចធារណ៍និរទោសអាចអនុវត្តបាននៅដំណាក់កាលបណ្តឹងសាទុក្ខដែលជាបញ្ហានៃសិទ្ធិស្របតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជា ដែលបានពន្លាតរហូតដល់“សាលក្រម*ជាស្ថាពរ*” ដូច្នេះហើយអង្គជំនុំជម្រះទទួលបានការជួយក្នុងកម្រិតតិចតួចប៉ុណ្ណោះ[121]។ អាស្រ័យហេតុនេះ ផ្ទុយទៅនឹងអ្វីដែលសហព្រះរាជអាជ្ញាបានអះអាង ភាពស្រដៀងគ្នាដែលបានបញ្ជាក់ខាងលើពុំអាចធ្វើជាមូលដ្ឋានដើម្បីអនុវត្តតាមគោលជំហររបស់តុលាការ ICTY ដែលជាជំហានមួយឈានទៅរកការមិនគោរពតាមក្របខ័ណ្ឌច្បាប់ជាធរមាននៅ អ.វ.ត.ក.។

61. ដូចការយល់ឃើញយ៉ាងត្រឹមត្រូវរបស់សហព្រះរាជអាជ្ញាថា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងជាពិសេសមាត្រា ១៤ ដែលត្រូវបានកម្ពុជាផ្តល់សច្ចាប័ន និងបានចម្លងដោយផ្ទាល់

---

[119] *រឿងក្តី Delić* កថាខណ្ឌ ១៥។

[120] មាត្រា ២១(៣) នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៃតុលាការ ICTY។

[121] មាត្រា ៣៨(៧) នៃរដ្ឋធម្មនុញ្ញកម្ពុជា។

ចូលទៅក្នុងក្រមខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.[122] បានដាក់បញ្ចូលបរិបទនៃសិទ្ធិទទួលបានការសន្មតថាឥតទោស ទៅក្នុងវិសាលភាពនៃកិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះដែលនៅពេលនោះការសន្មតនេះ បានដាក់បន្ទុកទៅលើអយ្យការក្នុងការបង្ហាញដល់តុលាការអង្គហេតុឱ្យហួសពីវិមតិសង្ស័យ នូវរាល់ធាតុផ្សំនៃបទល្មើសដែលជនជាប់ចោទត្រូវបានចោទប្រកាន់ ដើម្បីធានាបាននូវសាលក្រមដាក់ពិរុទ្ធភាព។ ប្រសិនបើមានវិមតិសង្ស័យសមហេតុផល ជនជាប់ចោទត្រូវតែសម្រេចឱ្យរួចខ្លួន[123]។

62. ដោយហេតុថា មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយមានលក្ខណៈស្មុគស្មាញយ៉ាងពិសេសដោយរួមបញ្ចូលនូវការធានាផ្សេង ដែលមានវិសាលភាពនៃការអនុវត្តន៍ខុសៗគ្នា គណៈកម្មាធិការស្តីពីសិទ្ធិមនុស្សបានបំភ្លឺយ៉ាងទូលំទូលាយក្នុងលក្ខណៈជាអនុសាសន៍ទូទៅ("អនុសាសន៍ទូទៅលេខ ៣២")ដើម្បីជួយដល់អ្នកអនុវត្តផ្ទាល់ដែលជារដ្ឋសមាជិកក្នុងការបកស្រាយមាត្រា ១៤ នៅពេលអនុវត្តសិទ្ធិនៃការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងយុត្តិធម៌[124]។ ការិយាល័យអង្គការសហប្រជាជាតិទៅកាន់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សសម្រាប់ប្រទេសកម្ពុជា បានបញ្ជាក់អំពីសារៈសំខាន់នៃការបំភ្លឺនេះសម្រាប់រដ្ឋភាគីទាំងអស់"ដោយមិនគិតថា រដ្ឋនោះប្រកាន់យកគោលការណ៍នៃប្រព័ន្ធច្បាប់ស៊ីវិល ឬអង់គ្លូសាក់សុង" និងចំពោះ"អ្នកអនុវត្តផ្ទាល់ដែលបានប្តេជ្ញាចិត្តអនុវត្តនូវសិទ្ធិនៃការទទួលការជំនុំជម្រះដោយត្រឹមត្រូវ និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា[125]។ អង្គជំនុំជម្រះចាត់ទុក**អនុសាសន៍ទូទៅ លេខ**

[122] មាត្រា ១៣ នៃកិច្ចព្រមព្រៀងបានយោងទៅលើមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែលចែងថា "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់"។ ពាក្យពេចន៍ប្រហាក់ប្រហែលគ្នាបានឆ្លុះបញ្ចាំងនៅក្នុងវិធាន ២១(១)(ឃ)ដែលចែងថា៖ "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ"។

[123] មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងមាត្រា ១១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សថា "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់នៅក្នុងការជំនុំជម្រះជាសាធារណៈ ដែលជននោះត្រូវទទួលបានរាល់ការធានាដែលចាំបាច់សម្រាប់ការការពារក្តីរបស់ខ្លួន"។

[124] អនុសាសន៍ទូទៅលេខ ៣២ គណៈកម្មាធិការស្តីពីសិទ្ធិមនុស្ស ឯកសាររបស់អង្គការសហប្រជាជាតិ CCPR/C/GC/32 ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ ("អនុសាសន៍ទូទៅលេខ ៣២")។

[125] ការិយាល័យអង្គការសហប្រជាជាតិទៅកាន់ឧត្តមស្នងការសម្រាប់សិទ្ធិមនុស្សនៅកម្ពុជា ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៥ និង ៧។ គេហទំព័រ http://cambodia.ohchr.org/sites/default/files/book/UNITED%20NATIONS%20GENERAL%20COMMENT%20NO%2032%20International%20Covenant%20on%20Civil%20and%20Political%20Rights%20Eng.pdf។

៣២ ជាការណែនាំបំភ្លឺនៅពេលអនុវត្តនូវការធានាផ្សេងៗជាអប្បបរមាដូចដែលមានចែងនៅក្នុងមាត្រា ១៤ ចំពោះបញ្ហាដែលបានលើកឡើងនៅក្នុងសំណើបន្ទាន់ ជាពិសេសអំណះអំណាងរបស់ នួន ជា ដែលថា ការអនុវត្តន៍ជាក់ស្តែងពាក់ព័ន្ធនឹងសច្ចធារណ៍និរទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ តម្រូវឱ្យមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូងនោះ។

63. បទប្បញ្ញត្តិក្នុងមាត្រា ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ រួមទាំងអនុសាសន៍ទូទៅលេខ ៣២ ដែលបានវែកញែកសិទ្ធិដែលអាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធីដំណាក់កាលជំនុំជម្រះ និងបណ្តឹងសាទុក្ខ[126] បានឆ្លុះបញ្ចាំងអំពីតួនាទីជាក់ស្តែងនៃសច្ចធារណ៍និរទោសនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលភាពមានពិរុទ្ធ ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទ និងភស្តុតាងដែលបានបង្ហាញដើម្បីដាក់បន្ទុក ឬដោះបន្ទុក គឺជាចំណុចស្នូល។ ទាំងនេះបានឆ្លុះបញ្ចាំងនៅក្នុងការកំណត់និយមន័យរបស់កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ អំពីសច្ចធារណ៍និរទោសដែលការពារជនជាប់ចោទ"រហូតដល់ត្រូវបានបង្ហាញថាមានពិរុទ្ធអនុលោមតាមច្បាប់"[127]។

64. ដោយហេតុថា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ត្រូវបានចម្លងចូលផ្ទាល់ទៅក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក. ក៏ដូចជាទៅក្នុងបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា[128]។ រដ្ឋធម្មនុញ្ញបានចែងច្បាស់លាស់ថា គោលការណ៍សច្ចធារណ៍និរទោសបន្តអត្ថិភាពរហូតដល់សាលក្រមស្ថាពរ ដែល

---

[126] អនុសាសន៍ទូទៅលេខ ៣២ ផ្តល់ការបំភ្លឺនូវភាពខុសគ្នារវាងសិទ្ធិក្នុងដំណើរការនីតិវិធីជាធរមាននៅពេលជំនុំជម្រះ និងដំណាលក់បណ្តឹងឧទ្ធរណ៍ ជៀសវាងការភាន់ច្រឡំក្នុងការប្រើប្រាស់ពាក្យពេចន៍។ សិទ្ធិនៅពេលជំនុំជម្រះត្រូវបានពិនិត្យយ៉ាងយកចិត្តទុកដាក់ និងពន្យល់នៅក្នុងជំពូក ៥ ស្តីពី"សិទ្ធិរបស់ជនដែលត្រូវបានចោទពីបទល្មើសព្រហ្មទណ្ឌ" ចំណែកសិទ្ធិនៅដំណាក់កាលបណ្តឹងសាទុក្ខមាននៅក្នុងជំពូក ៧ "ស្តីពីការពិនិត្យឡើងវិញដោយតុលាការជាន់ខ្ពស់"។

[127] មាត្រា ១៤(២) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ *សូមមើល* មាត្រា ១១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សដែលបានយោងផងដែរក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលចែងថា "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់នៅក្នុងការជំនុំជម្រះជាសាធារណៈដែលជននោះត្រូវទទួលបានរាល់ការធានាដែលចាំបាច់សម្រាប់ការការពារក្តីរបស់ខ្លួន"។

[128] មាត្រា ១២(១) និង (២) នៃកិច្ចព្រមព្រៀងចែងថា "ដំណើរការនីតិវិធីត្រូវតែស្របជាមួយច្បាប់កម្ពុជា" និង"អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចមានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលកម្ពុជាជាភាគីហត្ថលេខី"។

នេះមានន័យថា គោលការណ៍នេះអនុវត្តនៅដំណាក់កាលបណ្តឹងសាទុក្ខ ដែលជាបញ្ហានៃសិទ្ធិស្របតាមរដ្ឋធម្មនុញ្ញចំពោះពលរដ្ឋខ្មែរ។

65. ក្នុងតួនាទីជាអង្គជំនុំជម្រះតុលាការកំពូលដែលបានអនុវត្តបទដ្ឋានអន្តរជាតិ"នៅក្នុងរចនាសម្ព័ន្ធនៃតុលាការកម្ពុជា"[129] អង្គជំនុំជម្រះត្រូវប្រកាន់យកវិធីសាស្ត្រដែលមានលក្ខណៈទូលាយជាងក្នុងការយល់ឃើញថា សច្ចធារណ៍និរទោសត្រូវអនុវត្តទៅតាមបទដ្ឋាននៃការពិនិត្យឡើងវិញដោយចៅក្រមនៃអង្គជំនុំជម្រះ។ មានន័យថា សច្ចធារណ៍និរទោសពុំមែនក្នុងគោលបំណងប្រើប្រាស់តាមអត្ថន័យច្បាប់ដោយឥតខ្លឹមសារ ជាលក្ខណៈបុគ្គល ឬផ្នែកណាមួយនោះទេ ប៉ុន្តែជាលក្ខណៈទូទៅ និងតាមបរិបទ។ ទោះបីជាអង្គជំនុំជម្រះពុំអាចអនុវត្តពេញលេញតាមសេចក្តីសម្រេចក្នុង*រឿងក្តី Delić*[130]ក៏ដោយ ក៏អង្គជំនុំជម្រះយល់ស្របជាមួយនឹងការសង្កេតរបស់អង្គជំនុំជម្រះរបស់តុលាការ ICTY ពាក់ព័ន្ធនឹងភាពខុសប្លែកនៃ"បទដ្ឋានស្តីពីការពិនិត្យឡើងវិញជាធរមាននៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខដែលម្ចាស់បណ្តឹងសាទុក្ខមានបន្ទុកក្នុងការបង្ហាញកំហុសអង្គច្បាប់ ឬអង្គហេតុដែលធ្វើឱ្យសាលក្រមអង្គជំនុំជម្រះសាលាដំបូងមោឃៈ ឬនាំឱ្យមានភាពមិនយុត្តិធម៌ ជាជាងការប៉ុនប៉ងផ្តួចផ្តើមការជំនុំជម្រះ*សាជាថ្មី*"[131]។ សច្ចធារណ៍និរទោសដែលបន្តអនុវត្តនៅក្នុងតុលាការនេះ គឺជាលក្ខខណ្ឌតម្រូវដាច់ខាតចំពោះចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលក្នុងការវាយតម្លៃរាល់សារណាដែលបានធ្វើឡើងដោយម្ចាស់បណ្តឹងសាទុក្ខ ដោយមានការបើកចិត្តឱ្យទូលាយផ្អែកតាមបទដ្ឋានសមស្របក្នុងកម្រិតខ្ពស់[132]។

66. ប្រសិនបើ នួន ជា មានជីវិតរស់នៅ អង្គជំនុំជម្រះប្រាកដជាបានធ្វើការពិនិត្យលើបណ្តឹងសាទុក្ខនៃរឿងក្តីរបស់គាត់ ដោយអនុលោមតាមមាត្រា ៣៦ *ថ្មី* និងបានចេញ"សេចក្តីសម្រេចចុងក្រោយលើបញ្ហា

---

[129] បុព្វកថានៃកិច្ចព្រមព្រៀង។

[130] សេចក្តីសម្រេច*រឿងក្តី Delić* កថាខណ្ឌ ១៥ ដែលថា៖ "ការសន្មតថាឥតទោសពុំអានុវត្តចំពោះបុគ្គលដែលត្រូវបានសម្រេចដាក់ពិរុទ្ធភាពដោយអង្គជំនុំជម្រះសាលាដំបូងរង់ចាំដំណោះស្រាយនៃបណ្តឹងសាទុក្ខ"។

[131] សារណាតបរបស់សហព្រះរាជអាជ្ញា ជើងទំព័រ ១៩ *យោងទៅលើ*សេចក្តីសម្រេច*រឿងក្តី Delić* កថាខណ្ឌ ១៥។

[132] *រឿងក្តី Barberà, Messegué និង Jabardo ទល់នឹងប្រទេសអេស្ប៉ាញ* សាលក្រមរបស់តុលាការអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស សំណើលេខ 10590/83 ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៨៨ កថាខណ្ឌ ៧៧៖ នៅពេលអនុវត្តភារកិច្ច សមាជិកនៃតុលាការពុំគប្បីចាប់ផ្តើមក្នុងគំនិតគិតទុកជាមុនដែលថា ជនជាប់ចោទបានប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់"។

អង្គហេតុ និងអង្គច្បាប់”[133]។ ទោះជាយ៉ាងណាក្តី មរណភាពរបស់គាត់បាននាំឱ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធី និងក្នុងពេលដំណាលគ្នានោះ បានរារាំងលទ្ធភាពសម្រាប់ការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។

67. អង្គជំនុំជម្រះបញ្ជាក់សាជាថ្មីថា អង្គជំនុំជម្រះពុំមែនជាតុលាការអង្គហេតុដែលត្រូវបានកំណត់អំពីភាពមានពិរុទ្ធ ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទនោះទេ។ ទាំងនេះគឺជាមុខនាទីរបស់អង្គជំនុំជម្រះសាលាដំបូងតែមួយគត់។ មានការបែងចែកដាច់ច្បាស់លាស់រវាងវិធានផ្លូវច្បាប់ដែលចងកាតព្វកិច្ចអង្គជំនុំជម្រះតុលាការកំពូលឱ្យបើកចិត្តទូលាយក្នុងការពិនិត្យឡើងវិញលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង[134] និងសច្ចធារណ៍និរទោសដែលអនុវត្តចំពោះតុលាការអង្គហេតុ ដោយផ្អែកតាមសិទ្ធិទាំងអស់នៅក្នុងមាត្រា ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ វិធីសាស្ត្របែបនេះត្រូវបានកំណត់នៅក្នុងមាត្រា ៣៧ *ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ដែលចែងថា “ប្រការដែលបានចែងក្នុងមាត្រា ៣៣ ៣៤ និង ៣៥ ត្រូវអនុវត្ត*តាមករណីចាំបាច់*(*Mutatis mutandis*)ចំពោះការជំនុំជម្រះក្តីនៅអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល”។ Mutatis mutandis (តាមករណីចាំបាច់) មានន័យថា វិធានមួយត្រូវបានអនុវត្តដោយមានការកែប្រែឱ្យសមស្របទៅតាមកាលៈទេសៈ។ ហេតុដូច្នេះ ដោយផ្អែកលើភាពខុសគ្នានៅក្នុងយុត្តាធិការ កម្មវត្ថុ និងនីតិវិធីដែលអនុវត្តចំពោះអង្គជំនុំជម្រះសាលាដំបូង និងឧទ្ធរណ៍ សិទ្ធិនៅក្នុងការជំនុំជម្រះដែលត្រូវបានធានាដោយមាត្រា ១៤ នេះ តម្រូវឱ្យមានការសម្របសម្រួលនៅក្នុងការអនុវត្តន៍នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។ ជាចាំបាច់ ទាំងនេះត្រូវរួមបញ្ចូលការសម្របសម្រួល ដោយផ្អែកតាមទ្រឹស្តីនៃការអនុវត្តគោលការណ៍សច្ចធារណ៍និរទោស។

68. អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តីបានធ្វើការសន្និដ្ឋានដោយពុំត្រឹមត្រូវលើការអនុវត្តន៍នៃគោលការណ៍សច្ចធារណ៍និរទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ និងដោយភាន់ច្រឡំក្នុងការចាត់ទុកថាការអនុវត្តន៍នេះដូចគ្នាទៅនឹងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ អង្គជំនុំជម្រះបដិសេធអំណះអំណាងណាដែលថា ការអនុវត្តន៍សច្ចធារណ៍និរទោសចំពោះកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលបណ្តឹងសាទុក្ខ គឺមានន័យថា ម្ចាស់បណ្តឹងសារទុក្ខអាចចាប់ផ្តើមបណ្តឹងសារទុក្ខរបស់ខ្លួនបាន ក្នុងឋានៈដូចគ្នាជាជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ។

---

[133] មាត្រា ៣៦ *ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក.។

[134] *រឿងក្តី Barberà, Messegué និង Jabardo ទល់នឹង ប្រទេសអេស្ប៉ាញ* សាលក្រមរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សំណើលេខ 10590/83 ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៨៨ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស កថាខណ្ឌ ៧៧។

69. គោលការណ៍សច្ចធារណ៍និរទោស គឺជាវិធាននៃច្បាប់ដែលអនុវត្តនៅ អ.វ.ត.ក. រហូតដល់មានសេចក្ដីសម្រេចចុងក្រោយលើបណ្ដឹងសាទុក្ខដែលថាតើ ត្រូវតម្កល់ ឬបដិសេធការសម្រេចដាក់ពិរុទ្ធភាព។ គោលការណ៍សច្ចធារណ៍និរទោសពុំមែនជាការប្រកាសអំពីឋានៈថាឥតទោសនោះឡើយ។ ការបង្ហាញចេតនាក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីពិរុទ្ធភាព ពុំបានមោឃៈការយល់ឃើញនោះទេ។ ដោយសារបណ្ដឹងនេះពុំមែនជាការជំនុំជម្រះ*សាឡើងវិញ* ម្ចាស់បណ្ដឹងសាទុក្ខពុំបានចាប់ផ្ដើមបណ្ដឹងរបស់ខ្លួន ដោយបំពេញតាមការចែងអំពីសិទ្ធិយ៉ាងទូលំទូលាយនៅក្នុងមាត្រា ១៤ ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[135]។ ម្ចាស់បណ្ដឹងសាទុក្ខពុំបានឆ្លងកាត់ដំណាក់កាលបដិទានជាជនជាប់ចោទដោយសន្មតថាឥតទោសនោះឡើយ។ សច្ចធារណ៍និរទោសមានអត្ថិភាពចំពោះបទដ្ឋាននៃការពិនិត្យឡើងវិញ ដែលត្រូវអនុវត្តដោយអង្គជំនុំជម្រះតុលាការកំពូល។ បន្ថែមលើនេះ ដោយសារសច្ចធារណ៍និរទោស គឺជាសិទ្ធិបុគ្គលដែលអនុវត្តចំពោះបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខ ដូច្នេះមានន័យថា ប្រសិនបើម្ចាស់បណ្ដឹងសាទុក្ខស្លាប់នៅមុនការសម្រេចលើបណ្ដឹងសាទុក្ខរបស់ខ្លួន មរណភាពរបស់គាត់ធ្វើឱ្យរលត់បណ្ដឹងសាទុក្ខ និងសិទ្ធិផ្សេងៗជាធរមាននៅក្នុងដំណាក់កាលបណ្ដឹងសាទុក្ខនោះ។ មរណភាពនៅដំណាក់កាលបណ្ដឹងសាទុក្ខនេះពុំបានកែប្រែការយល់ឃើញអំពីពិរុទ្ធភាពនៅដំណាក់កាលជំនុំជម្រះ ទៅជាការយល់ឃើញថាគ្មានពិរុទ្ធភាពឡើយ។

## ង. ការបន្តកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខ

**សារណា**

70. ជាជម្រើសទៅនឹងការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខ មេធាវីការពារក្ដី នួន ជា បានស្នើសុំ“អង្គជំនុំជម្រះ ដើម្បីប្រយោជន៍យុត្តិធម៌ អនុញ្ញាតកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខបន្ត នៅពេលមានការធានាបាននូវការធ្វើជាតំណាងបន្តដោយមេធាវីការពារក្ដីក្រោយពេលមរណភាព នួន ជា តាមរយៈការជ្រើសរើសរបស់គាត់”[136]។ មេធាវីការពារក្ដីបានយោងទៅលើយុត្តាធិការដែលអនុញ្ញាតបណ្ដាំនៃបណ្ដឹងអាជ្ញា ឬការជំនួសឱ្យជនជាប់ចោទក្រោយពីមរណភាពនោះ[137] ឬការបន្តកិច្ចដំណើរការនីតិវិធីក្នុងករណីដែលមានភស្តុតាងបង្ហាញថា ម្ចាស់បណ្ដឹងសាទុក្ខដែលបានទទួលមរណៈនោះ ពុំបានប្រព្រឹត្ត

---

[135] *សូមមើលខាងលើ* កថាខណ្ឌ ៦៧។

[136] សំណើសុំបន្ទាន់ កថាខណ្ឌ ៣១ ៤៨ ដល់ ៥៦។

[137] *សូមមើលឧ.* សំណើសុំបន្ទាន់ កថាខណ្ឌ ៣១ និង ៥១ (យោងទៅលើការអនុវត្តក្នុងប្រទេសអង់គ្លេស និង វេល សិង្ហបុរី យុត្តាធិការផ្សេងៗរបស់សហរដ្ឋអាមេរិក កាណាដា ហុងកុង ចិត អ៊ីតាលី អាស៊ែរបៃហ្សង់ រុស្ស៊ី ស៊ុយអែត និងស្វីស)។

កំហុស[138]។ មេធាវីការពារក្ដីបានអះអាងថា ការបន្តយ៉ាងពិសេសនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខអាចជាលក្ខខណ្ឌតម្រូវ ដោយហេតុថា មាន“ភាពចាំបាច់ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ដើម្បីផលប្រយោជន៍សាធារណៈ ឬបញ្ហាជាប្រព័ន្ធទាក់ទងទៅនឹងរដ្ឋបាលតុលាការ” ដែលសំខាន់ជាងមរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខ[139]។ មេធាវីបានអះអាងបន្ថែមទៀតថា យុត្តាធិការលើរូបបុគ្គលនៃ អ.វ.ត.ក. ពុំមែនកម្រិតត្រឹមបុគ្គលដែលនៅរស់នោះទេ និងថា វិធាន ១១២(១) នៃវិធានផ្ទៃក្នុងបានអនុញ្ញាតឱ្យសាច់ញាតិជិតស្និទ្ធរបស់ម្ចាស់បណ្តឹងសាទុក្ខដែលស្លាប់នោះធ្វើបណ្តឹងសើរើលើសាលក្រមស្ថាពរ[140]។

71. សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំបានដាក់សារណាលើចំណុចនេះឡើយ។

**ការពិចារណា**

*(១) ការបន្តកិច្ចដំណើរការនីតិវិធី*

72. សារណារបស់មេធាវីការពារក្តីពាក់ព័ន្ធទៅនឹងការបន្តកិច្ចដំណើរការនីតិវិធី[141] ត្រូវបានចាត់ជាអសារបង់ ដោយផ្អែកលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលបញ្ចប់កិច្ចដំណើរការនីតិវិធីលើ នួន ជា[142]។

*(២) បណ្តឹងសើរើ*

73. វិធាន ១១២ នៃវិធានផ្ទៃក្នុងបានអនុញ្ញាតសំណើសុំប្តឹងសើរើលើសាលដីកាស្ថាពរ ដែលធ្វើឡើងដោយ“ទណ្ឌិត ឬក្នុងករណីដែលទណ្ឌិតនោះទទួលមរណភាព សហព័ទ្ធ កូន ឪពុកម្តាយ ឬបុគ្គលដទៃទៀតដែលមានជីវិតរស់រានទៅពេលមរណភាពរបស់ទណ្ឌិត ហើយបានទទួលនូវបណ្តាំជាលាយលក្ខណ៍អក្សរពីទណ្ឌិតឱ្យធ្វើបណ្តឹងសើរើ”។ លក្ខខណ្ឌនៃបណ្តឹងសើរើដែលអាចធ្វើឡើងនោះ គឺកម្រិតត្រឹម៖ (១) ភស្តុតាង

[138] *សូមមើលខ.* សំណើសុំបន្ទាន់ កថាខណ្ឌ ៥១ ដល់ ៥៥ (យោងទៅលើការអនុវត្តក្នុងប្រទេសអ៊ីតាលី អាស៊ែរបៃហ្សង់ រុស្ស៊ី និងចិន)។

[139] សំណើសុំបន្ទាន់ កថាខណ្ឌ ៥៥។

[140] សំណើសុំបន្ទាន់ កថាខណ្ឌ ៥ ដល់ ៦ និង ៦៥។

[141] សំណើសុំបន្ទាន់ កថាខណ្ឌ ២៩(ក) ៣០ ដល់ ៣៤, ៤៨ ដល់៥៦, ៦៩ ដល់ ៧៩។

[142] សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធី។

ថ្មីត្រូវបានរកឃើញដែលមិនអាចរកបាននៅពេលជំនុំជម្រះ និងនាំឱ្យសាលដីកាមានការប្រែប្រួល ប្រសិនបើផ្តល់ភស្តុតាងនេះឱ្យក្នុងពេលជំនុំជម្រះ (២) មានការរកឃើញថា ភស្តុតាងដែលត្រូវបានជំនុំជម្រះ និងយកមកធ្វើជាមូលដ្ឋាននៃការផ្តន្ទាទោសនោះ មានការក្លែងបន្លំ ឬ ខុសការពិត ឬ (៣) ចៅក្រមដែលបានចូលរួមនៅក្នុងការស៊ើបសួរ ឬការផ្តន្ទាទោសបានប្រព្រឹត្តខុសឆ្គងយ៉ាងធ្ងន់ធ្ងរនឹងក្រមសីលធម៌ ឬបំពានលើតួនាទីក្នុងការស្វែងរកយុត្តិធម៌ ដែលអាចនាំឱ្យមានការបណ្តេញចេញបានតាមវិធានផ្ទៃក្នុងនេះ។ បទប្បញ្ញត្តិនេះបង្ហាញពីលក្ខខណ្ឌតម្រូវខ្ពស់ចំពោះបណ្តឹងសើរើ។ សំណើសុំឱ្យសើរើលើកិច្ចដំណើរការនីតិវិធីដែលស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[143] បានដាក់លក្ខខណ្ឌជាមុនយ៉ាងតឹងរ៉ឹងដោយតម្រូវឱ្យសំណើនេះត្រូវតែទទួលបានការយល់ព្រមពីសភាពេញអង្គនៃតុលាការកំពូលមានសមត្ថកិច្ចលើបណ្តឹងសើរើ។

74. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា នួន ជា បានដាក់លិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរនៅមុនពេលមរណភាព ទៅឱ្យសមាជិកគ្រួសាររបស់គាត់ និងសហមេធាវីការពារក្តី អនុលោមតាមវិធាន ១១២ នៃវិធានផ្ទៃក្នុង"ដើម្បីបន្តកិច្ចដំណើរការនីតិវិធី ដាក់សារណា ឬផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីណាមួយនៅ អ.វ.ត.ក. ជំនួសរូបគាត់ ក្នុងករណីដែលគាត់ទទួលមរណភាព"[144]។ ទោះជាយ៉ាងណាក្តី វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានកម្រិតយ៉ាងជាក់ច្បាស់លើបណ្តឹងសើរើត្រឹម"សាលក្រមស្ថាពរ ឬសាលដីកាស្ថាពរ" និងត្រឹមលក្ខខណ្ឌជាក់លាក់ជាមុនដូចបានលើកឡើងខាងលើ[145]។ ដោយហេតុថា ពុំមានសាលក្រមស្ថាពររបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹង នួន ជា និងថា ពុំមានភស្តុតាងបង្ហាញ

---

[143] *សូមមើល* មាត្រា ៤៤៣ ដល់ ៤៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[144] លិខិតរបស់ នួន ជា ផ្ទេរសិទ្ធិទៅឱ្យបុគ្គលដែលបានជ្រើសរើសអនុវត្តជំនួសរូបគាត់ក្នុងករណីដែលគាត់ទទួលមរណភាពនៅមុនពេលការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F46 កថាខណ្ឌ ៩។

[145] *សូមមើល* វិធាន ១១២(៣) នៃវិធានផ្ទៃក្នុងចែងថា៖ "ការបើកំណត់[ដោយអង្គជំនុំជម្រះតុលាការកំពូល]បានថា ពាក្យសុំមានហេតុផលសមស្រប អង្គជំនុំជម្រះតុលាការកំពូលត្រូវមានយុត្តាធិការជំនុំជម្រះលើករណីនេះ ដើម្បីធ្វើសេចក្តីសវិនិច្ឆ័យថា តើត្រូវធ្វើការសើរើសាលក្រមនោះ ឬក៏អត់"។ មាត្រា ៤៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា៖ "បណ្តឹងសើរើ គឺជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រម និងសាលដីកាដែលស្ថាពរ ហើយដែលមាន*អជ្ជាអស់ជំនុំ*"។ មាត្រា ៤៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា៖ "អង្គជំនុំជម្រះតុលាការកំពូល "សម្រេចលើអង្គហេតុ និងអង្គច្បាប់ដោយសាលដីកាស្ថាពរ" កាលណាបើសភាព្រហ្មទណ្ឌសម្រេចថា បណ្តឹងសើរើអាចទទួលយកបាននោះ"។ មាត្រា ៤៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា៖ "ប្រសិនបើតុលាការកំពូលយល់ឃើញថា រឿងនោះល្មមជំនុំជម្រះបាន តុលាការកំពូលសម្រេចពីបណ្តឹងសើរើតាមសាលដីកាមួយដែលមិនអាចតវ៉ាបានទេ"។

ដើម្បីអាចពិចារណាលើសំណើបាន ដូច្នេះ សាលាក្រមអង្គជំនុំជម្រះសាលដំបូងពុំអាចធ្វើបណ្តឹងសើរើដោយផ្អែកតាមអត្ថន័យនៃវិធាន ១១២ នៃវិធានផ្ទៃក្នុងបានឡើយ។

75. អាស្រ័យហេតុនេះ និងទាក់ទងទៅនឹងចំណុចដែលពុំទាន់ត្រូវបានចាត់ទុកជាអសារបង់ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណារបស់មេធាវីការពារក្តីពាក់ព័ន្ធទៅនឹងការបន្តកិច្ចដំណើរការនីតិវិធីលើ នួន ជា។

## ច. ផលប៉ះពាល់នៃមរណភាពរបស់ នួន ជា ទៅលើសំណងដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង

**សារណា**

76. មេធាវីការពារក្តី នួន ជា បានទទួលស្គាល់ថា សាលក្រមចុងក្រោយគឺ"មានអត្ថប្រយោជន៍យ៉ាងខ្លាំងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី" ប៉ុន្តែគត់សម្គាល់ឃើញថា"សិទ្ធិរបស់ពួកគេក្នុងការទទួលបានសំណងអាចត្រូវបានបដិសេធចោល ប្រសិនបើកិច្ចដំណើរការនីតិវិធីត្រូវបញ្ចប់នៅក្នុងដំណាក់កាលនេះ"[146]។

77. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ទស្សនៈនេះជាការយល់ច្រឡំដោយសារ"វិធានការផ្តល់សំណង ដែលបានយល់ព្រមដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ត្រូវបានស្នើឡើងតាមរយៈវិធាន ២៣ *ស្ទួនបួន* ៣(ខ)នៃវិធានផ្ទៃក្នុងដែលចែងថា សំណង"ពុំជាប់ពាក់ព័ន្ធទៅនឹងជនជាប់ចោទជាក់លាក់ណាមួយ" និង"ពុំអាស្រ័យលើសាលក្រមឡើយ"។ ទាំងនេះបានបង្ហាញយ៉ាងច្បាស់ថា កម្មវិធីសំណងនៅក្នុងរឿងក្តីបច្ចុប្បន្ន [សំណុំរឿង ០០២/០២] ត្រូវបានបង្កើតឡើង និងត្រូវបានអនុវត្តស្របពេលជាមួយនឹងការជំនុំជម្រះ" និងវិធីសាស្ត្របែបនេះ"គឺស្របទៅនឹងគោលបំណងនៃវិធានផ្ទៃក្នុងដែលត្រូវបានអនុម័តដើម្បីអាចសម្រេចបានតាមរយៈម្ចាស់ជំនួយ និងអ្នកសហការពីខាងក្រៅនូវសំណងប្រកបដោយអត្ថន័យ"[147]។ អាស្រ័យហេតុនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

---

[146] សំណើបន្ទាន់ កថាខណ្ឌ ៧០។

[147] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១២។ *សូមមើលផងដែរ* ឯកសារលេខ E313 សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿងលេខ ០០២/០១ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១១២០។ ឯកសារលេខ E465 សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿងលេខ ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ កថាខណ្ឌ ៤៤១៨។ ('អង្គជំនុំជម្រះទទួលស្គាល់ថា ភាគច្រើននៃគំរោងនោះ ត្រូវបានអនុវត្តផ្នែកខ្លះ ឬទាំងស្រុង។ ក្នុងបរិបទនេះ អង្គជំនុំជម្រះរំលឹកថា ក្តីបារម្ភរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងការលំបាកជាក់ស្តែងក្នុងការធានាបាននូវការផ្តល់ថវិកាពីប្រភពខាងក្រៅសម្រាប់អនុវត្តគម្រោងសំណងតាមរយៈទម្រង់នៃការអនុវត្តន៍ដូចមានចែងក្នុងវិធាន

បានលើកឡើងថា មរណភាពរបស់ នួន ជា ពុំបានប៉ះពាល់ដល់ផ្នែកណាមួយនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងសំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើយ[148]។

78. សហព្រះរាជអាជ្ញាពុំបានឆ្លើយតបទៅនឹងចំណុចនេះទេ។

## ការពិចារណា

79. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា គម្រោងទាមទារសំណងដែលបានលើកឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានស្នើឡើងតាមរយៈវិធាន ២៣ ស្ទួន *បួន* (៣)(ខ)នៃវិធានផ្ទៃក្នុង[149]។ ក្នុងការអះអាងថា សំណងគឺអាស្រ័យលើសាលក្រមស្ពាពរ មេធាវីការពារក្តីពុំបានពិចារណាលើអត្ថន័យ និងអានុភាពនៃវិធាន ២៣ ស្ទួន *បួន* (៣)(ខ)នៃវិធានផ្ទៃក្នុងឡើយ ។

80. វិធាន ២៣ *ស្ទួនបួន* នៃវិធានផ្ទៃក្នុង បានផ្តល់លទ្ធភាពដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីរខុសៗគ្នាពុំអាចជំនួសគ្នាបានក្នុងការទាមទារសំណង[150]៖ ទីមួយ តម្រូវឱ្យទណ្ឌិតទទួលខុសត្រូវចេញសោហ៊ុយលើសំណង ទីពីរ អនុញ្ញាតឱ្យមាន"ការទទួលស្គាល់ថា គម្រោងជាក់លាក់មួយផ្តល់អានុភាពសមស្របទៅលើសំណងដែលស្នើឡើងដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអាចអនុវត្តបាន"។ វិធានផ្ទៃក្នុងតម្រូវថា សំណងស្នើឡើងតាមរយៈលទ្ធភាពទីពីរ"ត្រូវបានបង្កើតឡើង ឬកំណត់អត្តសញ្ញាណដោយមានការសហការជាមួយផ្នែកគាំពារជនរងគ្រោះ ហើយមានថវិកាគ្រប់គ្រាន់ផ្តល់ពីខាងក្រៅ"[151]។

---

២៣ *ស្ទួនបួន*(៣)(ខ)។ អង្គជំនុំជម្រះដោះស្រាយក្តីបារម្ភនេះនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ ដោយបានអនុញ្ញាត"ការចាប់ផ្តើមការអនុវត្តន៍គម្រោងនៅមុនសាលក្រម ដើម្បីធានាបាននូវការសម្រេចបាននូវសំណងប្រកបដោយអត្ថន័យនៅក្នុងពេលវេលាសមហេតុផល។ អង្គជំនុំជម្រះបានបញ្ជាក់សាជាថ្មីទៀតថា ទោះបីជាការសម្រេចដាក់ពិរុទ្ធភាពគឺជាលក្ខខណ្ឌដំបូងសម្រាប់ការផ្តល់សំណងជារួម និងផ្លូវចិត្តដោយអនុលោមតាមវិធាន ២៣ *ស្ទួនបួន* (១) នៃវិធានផ្ទៃក្នុង ការទទួលស្គាល់គម្រោងដែលការអនុវត្តន៍នៃគម្រោងនេះបានចាប់ផ្តើមរួចរាល់ហើយ ឬបានបញ្ចប់នោះ គឺស្របជាមួយនឹងគោលបំណងនៃវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង។

[148] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៣។

[149] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៤១៦។

[150] វិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង។

[151] វិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង។

81. ដោយហេតុថា វិសោធនកម្មដំបូងនៃវិធានផ្ទៃក្នុងបានអនុញ្ញាតការទាមទារសំណងតែឯកឯងពីទណ្ឌិត[152]។ វិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង ត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក. ដើម្បីអនុញ្ញាតសំណងដ៏មានអត្ថន័យអាចអនុវត្តបានតាមពេលវេលាសមស្របតាមរយៈការផ្តល់ថវិកាពីតតីយជន ឬការសហការជាមួយអង្គការរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល[153]។ ក្របខ័ណ្ឌការងារថ្មីនេះ ត្រូវបានបង្កើតឡើងដើម្បីទប់ទល់ទៅនឹងស្ថានការណ៍ឆ្លងកាត់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងសំណុំរឿង ០០១ ដែលបង្ហាញពី"លទ្ធភាពពុំអាចធ្វើទៅបានទាល់តែសោះ"ចំពោះ"ការទាមទារសំណងប្រឆាំងនឹងទណ្ឌិតនៃ អ.វ.ត.ក ហើយទទួលបានលទ្ធផលប្រកបដោយអត្ថន័យសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនោះ"[154]។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សំណងដែលទាមទារដោយស្របតាម "លទ្ធភាពផ្តល់សំណងថ្មី និងដាច់ដោយឡែកពីគ្នា ដែលបានបង្កើតឡើងដោយវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង[...]ពុំបានធ្វើឱ្យការទាមទារនេះអាចអនុវត្តបានចំពោះជនជាប់ចោទ ហើយសំណងនេះអាចបង្កើតឡើងបានក្នុងពេលដំណាលគ្នាជាមួយនឹងការជំនុំជម្រះ"[155]។

82. ក្នុងការទទួលស្គាល់នូវក្តីបារម្ភរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងការលំបាកជាក់ស្តែងក្នុងការធានាបាននូវការផ្តល់ថវិកាពីប្រភពខាងក្រៅសម្រាប់អនុវត្តគម្រោងសំណង

---

[152] *សូមមើលឧ.* វិធានផ្ទៃក្នុងនៃ អ.វ.ត.ក. វិសោធនកម្មលើកទី ៥ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០ វិធាន ២៣(១)*ស្ទួនបួន*នៃវិធានផ្ទៃក្នុងចាស់ចែងថា៖ "អង្គជំនុំជម្រះអាចសម្រេចផ្តល់ឱ្យតែសំណងផ្លូវចិត្ត និងសមូហភាពទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ការផ្តល់សំណងនេះត្រូវធ្វើឡើងប្រឆាំងនៅនឹងទណ្ឌិត និងជាបន្ទុករបស់ទណ្ឌិត"។ យោងតាមផ្នែក(២) ការផ្តល់សំណងអាចធ្វើឡើងក្រោមរូបភាពដូចតទៅ៖ "(ក) ការបង្គាប់ឱ្យបោះពុម្ពផ្សាយសាលក្រម ឬសាលដីកា នៅក្នុងសារព័ត៌មានសមស្របណាមួយដែលការចំណាយជាបន្ទុករបស់ទណ្ឌិត (ខ) ការបង្គាប់ឱ្យផ្តល់មូលនិធិដល់សកម្មភាព ឬសេវាកម្មរកប្រាក់ចំណេញណាមួយដែលមានគោលបំណងផ្តល់ប្រយោជន៍ដល់ជនរងគ្រោះ ឬ(គ) ទម្រង់ដទៃទៀតនៃសំណងដែលមានលក្ខណៈសមរម្យ និងប្របហាក់ប្រហែល"។

[153] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៤០៥ និង ៤៤១៨ (យោងទៅលើ៖ ការបញ្ជាក់ពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង។ វិធាន ៨០ *ស្ទួន* (៤) នៃវិធានផ្ទៃក្នុង)។ *សូមមើលផងដែរ* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក. ថា៖ សម័យប្រជុំកិច្ចប្រជុំពេញអង្គលើកទី ៨ បញ្ចប់ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០ គេហទំព័រ៖ https://www.eccc.gov.kh/en/Art.s/eight-eccc-plenary-session-concludes។

[154] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ E284 កថាខណ្ឌ ១៥៨ (ជើងទំព័រ ២៦៤)។

[155] សេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកិច្ចដំណើរការនីតិវិធីបន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ E284 កថាខណ្ឌ ១៥៨។

អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាត“ការចាប់ផ្តើមការអនុវត្តន៍គម្រោងនៅមុនសាលក្រម ដើម្បីធានាបាននូវការសម្រេចបាននូវសំណងប្រកបដោយអត្ថន័យនៅក្នុងពេលវេលាសមហេតុផល”[156]។ អង្គជំនុំជម្រះបានបញ្ជាក់សាជាថ្មីទៀតថា “ទោះបីជាការសម្រេចដាក់ពិរុទ្ធភាព គឺជាលក្ខខណ្ឌដំបូងសម្រាប់ការផ្តល់សំណងជារួម និងផ្លូវចិត្តដោយអនុលោមតាមវិធាន ២៣ *ស្ទួនបួន* (១) នៃវិធានផ្ទៃក្នុង ការទទួលស្គាល់គម្រោងដែលការអនុវត្តន៍នៃគម្រោងនេះបានចាប់ផ្តើមរួចរាល់ហើយ ឬបានបញ្ចប់នោះ គឺស្របជាមួយនឹងគោលបំណងនៃវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង”[157]។

83. អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានហេតុផលណាមួយត្រូវងាកចេញពីការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

84. មរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខ ពុំបានកែប្រែ ឬផ្លាស់ប្តូរការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុនេះ មរណភាពរបស់ នួន ជា ពុំបានប៉ះពាល់ដល់ការផ្តល់សំណងរបស់អង្គជំនុំជម្រះសាលាដំបូងដល់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសារកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខពុំមានអានុភាពណាមួយបង្អង់ការផ្តល់សំណង។ បើពុំដូច្នោះទេ ពុំស្របទៅនឹងកម្មវត្ថុ និងគោលបំណងនៃវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង ដោយសារបដិសេធនូវការអនុវត្តន៍គម្រោងផ្តល់សំណងក្នុងក្របខ័ណ្ឌពេលវេលាប្រកបដោយអត្ថន័យនោះឡើយ។

85. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា មរណភាពរបស់ នួន ជា ពុំមានអានុភាពលើការទទួលស្គាល់ព្យសនកម្មដែលទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី និងលើសំណងដែលបានសម្រេចដោយសាលក្រមអង្គជំនុំជម្រះសាលាដំបូងឡើយ។

## ឆ. សេចក្តីសង្ខេបនៃការបំភ្លឺផ្នែកច្បាប់

86. អង្គជំនុំជម្រះតុលាការកំពូលផ្តល់សេចក្តីបំភ្លឺផ្នែកច្បាប់ដូចខាងក្រោម៖

១. ការបញ្ចប់កិច្ចដំណើរការនីតិវិធី ពុំបានមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

---

[156] សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ០០២/០១ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E313 កថាខណ្ឌ ១១២០ និងសាលក្រមអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៤១៨។

[157] សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ០០២/០១ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E313 កថាខណ្ឌ ១១២០ និងសាលក្រមអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៤១៨។

២. ពុំមានបទប្បញ្ញត្តិចែងថាដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខដែលមានបំណងនោះ អាចបន្តក្រោយពេលមរណភាពរបស់ នួន ជា។

៣. សច្ចធារណ៍និរទោសមានអត្ថិភាពនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។

៤. សច្ចធារណ៍និរទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ គឺជាវិធាននៃច្បាប់ និងបទដ្ឋានដែលអនុវត្តដោយចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលក្នុងការពិនិត្យឡើងវិញលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ។

៥. ពុំមានការចេញសាលក្រម ឬសាលដីកាស្ថាពរលើភាពមានពិរុទ្ធ ឬគ្មានពិរុទ្ធរបស់ នួន ជា ដោយសារមរណភាពរបស់គាត់បានរារាំងការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។

៦. សច្ចធារណ៍និរទោសពុំមែនជាការយល់ឃើញថាគ្មានពិរុទ្ធ *ក្រោយមរណភាព*។

៧. មរណភាពរបស់ នួន ជា ពុំបានប៉ះពាល់ដល់ការផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី។

## V. ផ្នែកសម្រេចសេចក្តី

87. យោងតាមសម្អាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល៖**

**យល់ឃើញ**ថា សំណើបន្ទាន់នេះអាចទទួលយកបានតាមទម្រង់

**សម្រេចបដិសេធ**សំណើបន្ទាន់នេះចោល។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៩

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**